# ឱវាទបាតិមោក្ខ

## ចតុរង្គសន្និបាត. ព្រះអង្គទ្រង់ដាក់អាយុសង្ខារ



## រំលឹកដល់ថ្ងៃមាឃបូជា

រៀបរៀងដោយ ភិក្ខុ អភិធម្មបាលោ ម៉ុន ប៉ង់

ផ្សាយចេញពីវត្តប្រាសាទជាំងទង ( សម្រាប់ជាធម្មទាន )

# ថ្ងៃមាឃបូជា

## ទ្រង់សម្តែងឱវាទបាតិមោក្ខ

### ចតុរង្គសន្និបាត.    ព្រះអង្គទ្រង់ដាក់អាយុសង្ខារ



**រៀបរៀងដោយភិក្ខុ អភិធម្មបាលោ ម៉ុន ប៉ង់**

**ផ្សាយចេញពីវត្ត ប្រាសាទជាងទងឃុំស្វាយជ្រំ**

**ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង**

# អារម្ភកថា

ឱវាទបាតិមោក្ខគឺជា សាសនធម៌(ជាពាក្យប្រៀនប្រដៅ) របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ៗព្រះអង្គដែលត្រាស់ដឹងហើយតែងតែសម្តែង។

ខ្លឹមសារនៃ ឱវាទបាតិមោក្ខនេះគឺព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់សម្តែងអំពីគោលព្រះពុទ្ធសាសនា សំខាន់ៗជាបេះដូងនៃព្រះពុទ្ធសាសនា(ព្រះធម៌ព្រះវិន័យ)ជាព្រះពុទ្ធវចនៈដែលព្រះអង្គទ្រង់ត្រាស់ប្រកាសសម្តែងក្នុងគម្ពីរព្រះត្រៃបិដកទាំងអស់ គឺ

១- សព្វបាបស្ស អករណំ ការមិនធ្វើអំពើបាបទាំងពួងនេះសង្គ្រោះចូលទៅក្នុងព្រះវិន័យ(ជាសីល)

២- កុសលស្សូបសម្បទា ការបំពេញកុសលឲ្យដល់ព្រមនេះសង្គ្រោះចូលក្នុងព្រះសុត្តន្តបិដកដែលយើងច្រើនហៅថាព្រះសូត្រ(ជាសមាធិ)

៣- សចិត្តបរិយោទបនំ ការសម្អាតចិត្តរបស់ខ្លួនឲ្យផូរផង់នេះ

សង្គ្រោះចូលក្នុងព្រះអភិធម្ម(ជាបញ្ញា) នេះជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ។

ហើយសៀវភៅនេះដែរខ្ញុំបានដកស្រង់សេចក្តីពីគម្ពីរ ព្រះអដ្ឋកថា ព្រមទាំងដីកាទាំងឡាយ និងមានព្រះត្រៃបិដកជាគោល។ ដោយថាក្នុងថ្ងៃ១៥កើតខែមាឃជាថ្ងៃដែលពុទ្ធបរិស័ទប្រារព្ធកម្មវិធីបុណ្យមាឃបូជា ជារៀងរាល់ឆ្នាំ ដើម្បីរំឭកដល់ថ្ងៃ **ចតុរង្គសន្និបាត សម្ដែងឱវាទបាតិមោក្ខ និងរឭកដល់ថ្ងៃព្រះអង្គទ្រង់ដាក់ជន្មាយុសង្ខារ** ដូច្នេះហើយទើបខ្ញុំរៀបរៀងសៀវភៅនេះឡើង ដើម្បីឲ្យពុទ្ធបរិស័ទយកទៅសិក្សាស្វែងយល់ពីខ្លឹមសារ ដែលជាពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ និងដើម្បីស្វែងយល់នូវព្រឹត្តិការណ៍ក្នុងថ្ងៃ១៥កើតខែមាឃ ថាមានព្រឹត្តិការណ៍អ្វីខ្លះ។

ខ្ញុំសង្ឃឹមថាសៀវភៅនេះ និងក្លាយជាឯកសារជំនួយស្មារតីដល់ពុទ្ធបរិស័ទជាពិសេស សម្រាប់ភិក្ខុសាមណេរ និងឧបាសកឧបាសិកា យកទៅសិក្សាទ្រទ្រង់បដិបត្តិ

ដើម្បីរលាស់ខ្លួនចេញចាកទុក្ខ និងដើម្បីសម្រាប់ទ្រទ្រង់នូវព្រះពុទ្ធសាសនាអស់កាលជាអង្វែង។

សូមមេត្តាអធ្យាស្រ័យចំពោះរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមានឡើង ដោយអចេតនា មានទាំងខ្លឹមសារ ព្រមទាំងកំហុសផ្នែកអក្ខរាវិរុទ្ធផ្សេងៗ ក្នុងការរៀបរៀងសៀវភៅនេះឡើង ដោយក្តីអនុគ្រោះ។ ទន្ទឹមនេះផងដែរខ្ញុំសូមទទួលយកទស្សនៈ គំនិតតិចតៀន ពាក្យកែលម្អរបស់អស់លោកជាពុទ្ធបរិស័ទទាំងឡាយមានភិក្ខុ សាមណេរ ឧបាសក ឧបាសិកា ជាដើម ចំពោះការរិះគន់ក្នុងន័យស្ថាបនាដើម្បីឲ្យសៀវភៅនេះកាន់តែមានខ្លឹមសារល្អប្រសើរឡើង។

ថ្ងៃសុក្រ ១០កើត ខែ មិគសិរ ឆ្នាំថោះបញ្ចស័ក ព.ស២៥៦៧
វត្តប្រាសាទជាងទង ២២ ធ្នូ ២០២៣

**ភិក្ខុ ម៉ុន ប៉ង់ អភិធម្មធារោ**

# មាឃបូជា

ក្នុងថ្ងៃ ១៥ កើត ខែមាឃ ប្រារព្ធហេតុ ៣ ប្រការ ក្នុងព្រះពុទ្ធសាសនា

១- ជាថ្ងៃចតុរង្គសន្និបាតប្រកបដោយអង្គ ៤ គឺ

- ជាថ្ងៃពេញបូណ៌មី ១៥ កើត ព្រះច័ន្ទភ្លឺច្បាស់

- ព្រះភិក្ខុសង្ឃ ១២៥០ អង្គមកប្រជុំគ្នាដោយមិនបានណាត់ទុកជាមុន

-ភិក្ខុដែលមកប្រជុំគ្នាសុទ្ធតែជាព្រះខីណាស្រពបានអភិញ្ញា ៦

- ភិក្ខុសង្ឃទាំងអស់សុទ្ធតែបួសជាឯហិភិក្ខុឧបសម្បទា

២-ជាថ្ងៃដែលព្រះអង្គទ្រង់ត្រាស់សម្តែងនូវឱវាទបាតិមោក្ខ(បេះដូងព្រះពុទ្ធសាសនា)

៣-ជាថ្ងៃដែលព្រះបរមសាស្តាដាក់ជន្មាយុសង្ខារចំពោះមុខមារ ។( រួមនិងថ្ងៃព្រះអគ្គធម្មសេនាបតីសារីបុត្ត បានសម្រេច

ជាព្រះអរហន្ត ហើយទ្រង់ស្ដាបនាអគ្គសាវ័កស្ដាំ/ឆ្វេងក្នុងថ្ងៃនោះដែរ)។

សូមពុទ្ធបរិស័ទទាំងឡាយ ធ្វើនូវសក្ការៈបូជាចំពោះព្រះរតនៈត្រៃក្នុងថ្ងៃសំខាន់ៗក្នុងព្រះពុទ្ធសាសនា តាមសេចក្ដីជ្រះថ្លារបស់ខ្លួន ធ្វើទាន រក្សាសីល ចម្រើនភាវនាគ្រប់ៗគ្នាកុំបីអាក់ខានឡើយ។

# មាតិកា

១.ចតុរង្គសន្និបាត.................................................................១
២.ឱវាទបាតិមោក្ខគាថា.....................................................៩
បំភ្លឺឱវាទបាតិមោក្ខ..........................................................១៣
គាថាទី១ ...........................................................................១៣
គាថាទី២...........................................................................១៨
គាថាទី៣ ..........................................................................២៩
បំភ្លឺគាថា .........................................................................២៩
៣ ទ្រង់ដាក់អាយុសង្ខារ.....................................................៣៧
ទ្រង់យាងចូលសម្រាកនៅឯបាវាលចេតិយ ............................៣៧
ហេតុនៃការកក្រើកផែនដី៨យ៉ាង.........................................៤៧
បរិសទ៍៨ពួក .......................................................................៥២
ព្រះអានន្ទទូលឃាត់អង្វរព្រះមានព្រះតាគសូមឲ្យព្រះអង្គគង់អស់ ១ អាយុកប្ប.... ៥៨

សេចក្តីពន្យល់របស់ព្រះអដ្ឋកថា .................................... ៧៣
វិធីប្រកាសមាឃបូជា ..................................................... ៨១
វេរគ្រឿងសក្ការៈបូជា ទាំងបាលី និងសម្រាយ ........................... ៨៧
នមោ៨បទ ............................................................ ៩០
ពាក្យសរសើរគុណព្រះរតនត្រ័យ!! .................................. ៩២
គាថាពោលសរសើរព្រះគុណព្រះសម្មាសម្ពុទ្ធជាម្ចាស់ .............. ១០១
ម្ភៃប្រាំពីរតែបែរ ..................................................... ១០៣
ឥន្ទកវត្តសូត្រ ....................................................... ១០៧
តាយនសុត្តគាថា ..................................................... ១០៩
ខេមាខេមសរណទីបិកគាថា ........................................... ១១១
អភិណ្ហប្បច្ចវេក្ខណា: ............................................... ១១៣
បព្វជិតអភិណ្ហប្បច្ចវេក្ខណធម្មោ ១០ ................................. ១១៥
ធម្មនិយាម ៣០ ..................................................... ១១៨

## សូមនមស្ការចំពោះព្រះដ៏មានព្រះភាគ

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**

**សព្វញ្ញូសិ មហាវីរ លោកជេដ្ឋ នរាសភ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញូពុទ្ធ។

**លាភាលាភេ ន សជ្ជន្តិ សម្មានេ វិមានេ**

**បឋវីសទិសា ពុទ្ធា តស្មា តេ ន វិរោធិយា ។**

ព្រះពុទ្ធទាំងឡាយ មានចិត្តស្មើរដោយផែនដី មិនជាប់ជំពាក់ក្នុងលាភ និង អលាភ ក្នុងការរាប់អាន ក្នុងការមើលងាយ ហេតុនោះបុគ្គលមិនគប្បីឱ្យឆ្គាំឆ្គងនឹងព្រះពុទ្ធទាំងនោះឡើយ ។



# ១.ចតុរង្គសន្និបាត

( ទ្រង់សម្ដែងឱវាទបាតិមោក្ខ )

( ក្នុងថ្ងៃ១៥កើត ពេញបូណ៌មី ខែមាឃ ឆ្នាំរការ )

ធម្មតាព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយដែលបានត្រាស់ដឹងក្នុងអតីតកាលកន្លងហើយ តាំងពីព្រះវិបស្សីសម្មាសម្ពុទ្ធជាដើមក្ដី ព្រះអរហន្តសម្មាសម្ពុទ្ធដែលនឹងបានត្រាស់ក្នុងអនាគតកាលខាងមុខក្ដី ព្រះអរហន្ត

សម្មាសម្ពុទ្ធជាបរមគ្រូរបស់យើងទាំងឡាយ ដែលមានសាសនាវាទរុងរឿងនៅសព្វថ្ងៃនេះក្តី ព្រះសម្មាសម្ពុទ្ធក្នុងកាលទាំង ៣តែងទ្រង់ធ្វើវិសុទ្ធិឧបោសថសម្តែងឱវាទបាតិមោក្ខ ៣ គាថានេះក្នុងទីប្រជុំនៃព្រះសង្ឃសាវ័កដ៏ប្រសើរ ដែលហៅថា **ចតុរង្គសន្និបាត** (ការប្រជុំសាវ័កប្រកបដោយអង្គ ៤) ដូចគ្នាគ្រប់ៗ អង្គ ផ្សេងតែវារៈដែលទ្រង់សម្តែង ព្រះអង្គខ្លះច្រើនដង ព្រះអង្គខ្លះតិចដង និងផ្សេងចំនួនភិក្ខុដែលមកប្រជុំ ច្រើនតិចជាងគ្នាតាមកាលដូចដែលទ្រង់សម្តែងទុកហើយ

ព្រះទីបង្ករសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ ដង គឺមានភិក្ខុ ១សែនកោដិរូបម្តង១រយកោដិរូបម្តងនិង៩០កោដិម្តង

ព្រះកោណ្ឌញ្ញៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដង គឺមានភិក្ខុ ១សែនកោដិរូបម្តង ១ពាន់កោដិរូបម្តង និង៩០កោដិរូបម្តង

ព្រះមង្គលៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដង គឺមាន

ភិក្ខុ ១កោដិរូបម្តង១សែនកោដិរូបម្តងនិង៩០កោដិរូបម្តង
ព្រះសុមនៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដង គឺមាន ភិក្ខុ១សែនកោដិរូបម្តង ៩០កោដិរូបម្តងនិង៨០កោដិម្តង
ព្រះរេវតៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដង គឺមាន ភិក្ខុច្រើនហួសគណនាម្តង ១សែនកោដិរូបម្តងនិងលើក ទី៣ មានភិក្ខុ១សែនកោដិរូបម្តង
ព្រះសោភិតៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដង គឺមាន ភិក្ខុ១រយកោដិរូបម្តង ៩០កោដិរូបម្តងនិង៨០កោដិរូបម្តង
ព្រះអនោមទស្សីសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដងគឺ មានភិក្ខុ៨សែនរូបម្តង ៧សែនរូបម្តង និង៦សែនរូបម្តង
ព្រះបទុមសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដងគឺមានភិក្ខុ ១សែនកោដិរូបម្តង ៣សែនរូបម្តង និង២សែនរូបម្តង
ព្រះនារទៈសម្មាសម្ពុទ្ធមានចតុរង្គសន្និបាត ៣ដងគឺមានភិក្ខុ ១សែនកោដិរូបម្តង ៩០ពាន់កោដិរូបម្តងនិង៨០សែនម្តង
ព្រះបទុមុត្តរៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដងគឺមាន

ភិក្ខុ១សែនកោដិរូបម្តង ៩០ពាន់កោដិរូបម្តងនិង៨០ពាន់កោដិរូបម្តង

ព្រះសុមេធៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដងគឺមានភិក្ខុ១រយកោដិរូបម្តង៩០កោដិរូបម្តងនិង៨០កោដិរូបម្តង

ព្រះសុជាតៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដងគឺមានភិក្ខុ ៦០សែនរូបម្តង ៥០សែនរូបម្តងនិង៤សែនរូបម្តង

ព្រះបិយទស្សីសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដងគឺមានភិក្ខុ ១សែនកោដិម្តង ៩០កោដិរូបម្តងនិង៨០កោដិរូបម្តង

ព្រះអត្ថទស្សីសម្មាសម្ពុទ្ធ មានចតុរង្គសន្និនិបាត ៣ដងគឺមានភិក្ខុ៩៨ពាន់រូបម្តង ៨៨ពាន់រូបម្តងនិង៧៨ពាន់ម្តង

ព្រះធម្មទស្សីសម្មាសម្ពុទ្ធ មាចតុរង្គសន្និបាត ៣ដងគឺមានភិក្ខុ១ពាន់កោដិរូបម្តង ១រយកោដិរូបម្តងនិង៨០កោដិម្តង

ព្រះសិទ្ធត្ថៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដងគឺមានភិក្ខុ១រយកោដិរូបម្តង ៩០កោដិរូបម្តងនិង៨០កោដិរូបម្តង

ព្រះតិស្សៈសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ដង គឺមាន

ភិក្ខុ ១សែនរូបម្តង ៩០សែនរូបម្តងនិង៨០សែនរូបម្តង
ព្រះបុស្ស:សម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត៣ដង គឺមាន
ភិក្ខុ ៦០សែនរូបម្តង ៥០សែនរូបម្តងនិង៤០សែនរូបម្តង
ព្រះវិបស្សីសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ ដង គឺមាន
ភិក្ខុ៦លាន៨សែនរូបម្តង. ១សែនរូបម្តងនិង៨ម៉ឺនរូបម្តង
ព្រះសិខីសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ ដង គឺមាន
ភិក្ខុ ១ សែនរូបម្តង ៨ ម៉ឺនរូបម្តង.មានភិក្ខុ៧ម៉ឺនរូបម្តង។
ព្រះវេស្សភូសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ ដង គឺមាន
ភិក្ខុ ៨ ម៉ឺនរូបម្តង ៧ ម៉ឺនរូបម្តង និង៦ ម៉ឺនរូបម្តង។
ព្រះកកុសន្ធ:សម្មាសម្ពុទ្ធ មានចតុរង្គសន្និបាតតែម្តង គឺ
មានភិក្ខុ៤ម៉ឺនរូប។
ព្រះកោនាគមន:សម្មាសម្ពុទ្ធ មានចតុរង្គសន្និបាតតែម្តងគឺ
មានភិក្ខុ៣ម៉ឺនរូប។
ព្រះកស្សបសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាតតែម្តង មាន
ភិក្ខុ២ម៉ឺនរូប.។

ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមគោតមបរមគ្រូនៃយើងមាន ចតុរង្គសន្និបាតតែម្តងគត់មានភិក្ខុជាព្រះអរហន្តសាវ័ក ដែលមកប្រជុំគ្នាក្នុងគ្រានោះមាន(១២៥០)១ពាន់២រយ ៥០សិបរូបប៉ុណ្ណោះតិចជាងព្រះសម្មាសម្ពុទ្ធពីបុរាណ។ ចតុរង្គសន្និបាតរបស់ព្រះសម្មាសម្ពុទ្ធពីបុរាណដូច្នេះគឺ

១- សព្វេ ឯហិភិក្ខុ ភិក្ខុទាំងអស់សុទ្ធតែជាឯហិភិក្ខុ

២- សព្វេ ឥទ្ធិយា និព្វត្តបត្តចីវរា ភិក្ខុទាំងអស់សុទ្ធតែមាន បាត្រនិងចីវរកើតឡើងដោយឫទ្ធិ

៣- សព្វេ អនាមន្តិតាវ អាគតា ភិក្ខុទាំងអស់សុទ្ធតែមកឥត នរណានិមន្ត

៤-បណ្ណរសេឧបោសថទិវសេមកក្នុងថ្ងៃឧបោសថ១៥កើត។

ចតុរង្គសន្និបាត របស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងនេះ ដូច្នេះគឺ

១- មាឃនក្ខត្តេន យុត្តោ បុណ្ណមីឧបោសថ ទិវសោ ថ្ងៃ ឧបោសថ ព្រះចន្ទពេញវង់ប្រកបដោយផ្កាយប្រចាំខែ

មាឃៈ គឺថ្ងៃ ១៥ កើតខែមាឃ
២- តេនចិ អនាមន្តិតានិ ហុត្វា អត្តនោយេវ ធម្មតាយ សន្និបតិតានិ អឌ្ឍតេរសានិ ឥក្ខុសតានិ ភិក្ខុ ១២៥០ រូប ឥតមាននរណានិមន្តទៀយ ស្រាប់តែមកប្រជុំគ្នាតាមធម្មតារបស់លោក
៣- តេសុ ឯកោ បុថុជ្ជនោ វា សោតាបន្ន សកទាគាមិអនាគាមិសុក្ខវិបស្សអរហន្តេសុ វា អញ្ញតរោ នត្ថិ សព្វេ ឆ អតិញ្ញាវ ភិក្ខុអម្បាលនោះជាបុថុជ្ជន ឬសោតាបន្ន សកទាគាមី អនាគាមី ឬព្រះអរហន្តសុក្ខវិបស្សកៈ សូម្បីតែ ១ រូបក៏មិនមាន សុទ្ធតែជាព្រះអរហន្ត បានអភិញ្ញាណ ៦ គ្រប់រូប
៤- ឯកោបិ ចេត្ថ សត្ថកេន កេសេ ឆិន្ទិត្វា បព្វជិតោ នាម នត្ថិ សព្វេ ឯហិភិក្ខុយេវ សូម្បីតែ ១ រូបដែលកោរសក់ដោយកាំបិតហើយបួសក៏មិនមាន សុទ្ធតែជាឯហិភិក្ខុទាំងអស់។

ចតុរង្គសន្និបាតនេះ ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើងទ្រង់ធ្វើក្នុងវត្តវេឡុវ័ន។ មានដំណាលថា កាលដែលព្រះអគ្គសាវ័កទាំងពីរបួសហើយព្រះមហាមោគ្គល្លានបាន

សម្រេចអរហត្តក្នុងថ្ងៃទី៧ ។ ព្រះធម្មសេនាបតីសារីបុត្ត បានសម្រេចសាវកបារមីញាណក្នុងថ្ងៃទី ១៥ នៅវេលា ដែលបញ្ជូនញាណទៅតាមខ្សែធម្មទេសនា ដែលព្រះដ៏ មានព្រះភាគទ្រង់សម្ដែង វេទនាបរិគ្គហសូត្រ ប្រោសទីឃ នខបរិព្វាជកជាក្មួយរបស់លោកក្នុងញកគុហាឈ្មោះ សូករខាតលេណៈនាពាក់កណ្ដាលភ្នំគិជ្ឈកូដ។ កាល ដែលព្រះដ៏មានព្រះភាគទ្រង់ជ្រាបថាព្រះថេរៈបាសម្រេច អរហត្តហើយព្រះអង្គទ្រង់ហោះទៅតាមអាកាស ប្រតិស្ឋានឯវត្តវេឡុវ័ន។ ព្រះថេរៈបានជ្រាបដូច្នោះ ក៏ហោះ ទៅតាមអាកាសប្រតិស្ឋានក្នុងវត្តវេឡុវ័នដែរ។ សម័យ នោះជាវេលាជួបជុំប្រកបដោយអង្គ ៤ដែលហៅថា ចតុរង្គ សន្និបាតព្រះដ៏មានព្រះភាគក៏ទ្រង់សម្ដែងឱវាទបាតិមោក្ខ ក្នុងទីប្រជុំនោះ។

# ២.ឱវាទបាតិមោក្ខគាថា

សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ១៦ទំព័រ ១០៣ និងសុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា ពុទ្ធវគ្គលេខ៥២ទំព័រ៦០

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**

**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ។**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ។

**ខន្តិ បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ។**

អំណត់ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ខ្ពង់ខ្ពស់ ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតិដ៏ខ្ពង់ខ្ពស់ អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ។

**អនូបវាទោ អនូបឃាតោ, បាតិមោក្ខេ ច សំវរោ មត្តញ្ញុតា ច ភត្តស្មិំ, បន្តញ្ច សយនាសនំ;អធិចិត្តេ ច អាយោគោ, ឯតំ ពុទ្ធាន សាសនំ។**

កិរិយាមិនតិះដៀល(អ្នកដទៃ) ១ កិរិយាមិនបៀតបៀន(អ្នកដទៃ) ១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវៈជាអ្នកដឹងប្រមាណក្នុងភត្តាហា ១ ទីរដេកនិងទីអង្គុយដ៏ស្ងាត់ ១ ការព្យាយាមក្នុងអធិចិត្ត១ទាំងនេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ៗ

ក្នុងសមន្តប្បាសាទិកា បាលី ប្រែ ភាគ២ទំព័រ ២៨២ ត្រង់វេរញ្ជកណ្ឌ បញ្ជាក់ថាៈ

គប្បីជ្រាបថាបាតិមោក្ខទ្ទេសរបស់ព្រះពុទ្ធទាំងឡាយក្រៅនេះ ក៏មានន័យដូចគ្នា។ មែនពិតព្រះពុទ្ធគ្រប់ព្រះអង្គមានព្រះឱវាទបាតិមោក្ខគាថាត្រឹមតែ ៣ គាថានេះប៉ុណ្ណោះ។ គាថាទាំងនោះរមែងមកកាន់ឧទ្ទេសរហូតដល់ទីបំផុតនៃព្រះពុទ្ធសាសនារបស់ព្រះពុទ្ធទាំងឡាយ ដែលមានព្រះជន្មាយុវែង។ តែសម្រាប់ព្រះពុទ្ធទាំងឡាយដែល

មានព្រះជន្មាយុខ្លី គាថាទាំងនោះ មកកាន់ឧទ្ទេសតែក្នុងបឋមពោធិកាលប៉ុណ្ណោះ។ត្បិតថាចាប់ផ្ដើមអំពីកាលទ្រង់បញ្ញត្តសិក្ខាបទមកក៏សម្ដែងចំពោះតែ អាណាបាតិមោក្ខប៉ុណ្ណោះ។

ក៏អាណាបាតិមោក្ខនោះ ពួកភិក្ខុប៉ុណ្ណោះសម្ដែង ព្រះពុទ្ធទាំងឡាយទ្រង់មិនសម្ដែងទេ។ ព្រោះហេតុនោះព្រះមានព្រះភាគនៃយើង ទ្រង់សម្ដែងឱវាទបាតិមោក្ខនេះបានត្រឹមតែ២០វស្សាក្នុងបឋមពោធិកាលប៉ុណ្ណោះ។ តមកថ្ងៃមួយព្រះមានព្រះគាគ ទ្រង់គង់ក្នុងប្រាសាទរបស់មិគារមាតាក្នុងបុព្វារាម បានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយក្នុងកាលឥឡូវនេះ តាំងពីថ្ងៃនេះតទៅមុខតថាគតនឹងធ្វើឧបោសថមិនសម្ដែងបាតិមោក្ខទេម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ចាប់តាំងអំពីថ្ងៃនេះទៅមុខចូរអ្នកទាំងឡាយនាំគ្នាធ្វើឧបោសថសម្ដែងបាតិមោក្ខចុះ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងធ្វើឧបោសថ សម្ដែង

បាតិមោក្ខ ជាមួយនឹងបរិស័ទមិនបរិសុទ្ធ ដោយហេតុណា ហេតុនោះមិនមែនជាឋានៈ មិនមែនជាឱកាស(ល្មមនឹងធ្វើបានទេ)។ តាំងអំពីនោះមក ពួកភិក្ខុក៏សម្តែង អាណាបាតិមោក្ខ។

ក្នុងសម័យព្រះបរមគ្រូនៃយើង ការជួបជុំភិក្ខុសង្ឃបែបនេះមានតែម្តងគត់ គឺក្នុងឆ្នាំដំបូងក្រោយអំពីព្រះអង្គត្រាស់ដឹងហើយបាន ៩ ខែ។

# បំភ្លឺខុទ្ទកនិកាយ

## គាថាទី១

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំៗ

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាយបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ។

## បំភ្លឺគាថា

គាថាធម្មបទពន្យល់ថាបទថា **សព្វបាបស្ស** (នូវបាបទាំងពួង)បានដល់អកុសលកម្មគ្រប់យ៉ាង។

សារត្ថទីបនីដីកា ពន្យល់ថា **សព្វបាបស្ស** ប្រែថា អកុសលទាំងពួងគឺអកុសលទាំង១២ បានដល់ធម៌ដែលប្រកបដោយ ទោស ដែលសង្គ្រោះដោយចិត្តុប្បាទទាំងពួង។ បទថា **អករណំ** (កិរិយាមិនធ្វើ) បានដល់ការមិនធ្វើឲ្យ

កើតឡើង។ មែនពិតការមិនញុំាងបាបធម៌ទាំងនោះឲ្យកើតក្នុងសន្តានរបស់ខ្លួនឈ្មោះថាការធ្វើ ព្រោះដូច្នោះការមិនធ្វើដោយការហាមនូវបាបទាំងពួងនោះទើបឈ្មោះថាមិនធ្វើឲ្យកើតឡើង។

**សុមង្គលវិលាសិនី** ពន្យល់ថាបទថា **អករណំ** (កិរិយាមិនធ្វើ) គឺមិនធ្វើឲ្យកើតឡើង។

បទថា កុសលស្ស (នូវកុសល) បានដល់កុសលដែលមាននូវក្នុងភូមិ៤។

សារត្ថទីបនីដីកាបទថាៈកុសលស្ស (នូវកុសល)បានដល់កុសលដែលប្រព្រឹត្តទៅក្នុងភូមិទាំង៤។ ក៏ពាក្យថា កុសលស្ស នេះរមែងធ្វើឲ្យយល់ដល់ធម៌ គឺអរិយមគ្គ និងធម៌ទាំងឡាយដែលជាកុសលដែលប្រព្រឹត្តទៅ ក្នុងភូមិ៣ ដែលជាអង្គរបស់ធម៌ គឺអរិយមគ្គនោះព្រោះព្រះអង្គត្រាស់តទៅទៀតថា **ឯតំពុទ្ធាន សាសនំ** ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ។

**ឧបសម្បទាតិ អភិនិក្ខមនតោ បដ្ឋាយ យាវ អរហត្តមគ្គា កុសលស្ស ឧប្បាទនញ្ចេវ ឧប្បាទិតស្ស ច ភាវនា។**

ការញ៉ាំងកុសលឲ្យកើតឡើង ចាប់ផ្តើមតាំងអំពីការចេញបួសដរាបដល់សម្រេចអរហត្តមគ្គ និងការញ៉ាំងកុសលដែលខ្លួនបានធ្វើឲ្យកើតឡើងហើយឲ្យចម្រើនឡើង ឈ្មោះថា ឧបសម្បទា។

បទថា ឧបសម្បទា (ធម្មជាតិជាហេតុដល់ព្រម)គឺការបានចំពោះ។

សារត្ថទីបនីដីកាបទថា ឧបសម្បទា ប្រែថាការចូលទៅឲ្យដល់ព្រម។ ក៏ការចូលឲ្យដល់ព្រមនោះ ដោយអត្ថ បានដល់ការចាក់ធ្លុះ គឺការបានចំពោះនូវកុសលនោះ។

សុមង្គលវិលាសិនី បទថា **សចិត្តបរិយោទបនំ** គឺការញ៉ាំងចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់។ ក៏ពាក្យនេះរមែងបានដោយភាពជាព្រះអរហន្ត។បព្វជិតគួរលះបង់នូវបាបទាំងពួងដោយសីលសំវរ:(ការសង្រួមក្នុងសីល) ញ៉ាំងកុសលឲ្យ

ដល់ព្រមដោយសមថៈនិងវិបស្សនាទាំងឡាយញ៉ាំងចិត្ត ឲ្យផូរផង់ដោយអរហត្តផល នេះជាពាក្យទូន្មានគឺជាឱវាទ ជាពាក្យទូន្មានប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ។

ការញ៉ាំងចិត្តរបស់ខ្លួនឲ្យផូរផង់ចាកនីវរនធម៌ទាំង៥ ឈ្មោះថា **សចិត្តបរិយោទបនំ**។

សារត្ថទីបនីដីកាបទថា **សចិត្តបរិយោទបនំ** បានដល់ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ គឺការធ្វើសេចក្តីបរិសុទ្ធដល់ចិត្ត បានដល់ការឲ្យបរិសុទ្ធដោយជុំវិញដោយប្រការទាំងពួង។ ក៏ការធ្វើចិត្តរបស់ខ្លួនឲ្យបរិសុទ្ធនោះ រមែងមានបានដោយភាវៈជាព្រះអរហន្ត។និងក្នុងអធិការនេះព្រោះចិត្តរបស់អ្នកដែលមានសេចក្តីព្រមព្រៀងដោយមគ្គដ៏ប្រសើរ រមែងឈ្មោះថា កំពុងបរិសុទ្ធដោយប្រការទាំងពួង។ ចំណែកក្នុងខណៈនៃផលដ៏ប្រសើរ រមែងជាធម្មជាតិបរិសុទ្ធហើយ ព្រោះមិនមានភាវៈដែលនិងគប្បីធ្វើឲ្យបរិសុទ្ធតទៅទៀត។ ព្រោះដូច្នោះទើបខ្ញុំពោលទុកថា ការធ្វើចិត្តរបស់ខ្លួនឲ្យ

បរិសុទ្ធនោះរមែងមានបានដោយភាព ជាព្រះអរហន្តដូច្នេះ សំដៅដល់ភារៈគឺសេចក្ដីបរិសុទ្ធដែលសម្រេចហើយ។ បទថា **ឯតំពុទ្ធានសាសនំ** (ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ) ដោយអត្ថថាឱវាទ  នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ៗព្រះអង្គ។

**ឥតិ សីលសំវរេន សព្វបាបំ បហាយ លោកិយលោកុត្តរេហិ សមថវិបស្សនាហិ កុសលំ សម្បាទេត្វា អរហត្តផលេន ចិត្តំ បរិយោទបេតព្វន្តិ ឯវំ ពុទ្ធានំ សាសនំ ឱវាទោ អនុសិដ្ឋីៗ**ពាក្យថាបុគ្គលគប្បីលះនូវបាបទាំងពួង ដោយសីលសំវរៈ ហើយញុំាងកុសលឲ្យដល់ព្រមដោយសមថៈ និងវិបស្សនា ដែលជាលោកិយ និងលោកុត្តរៈហើយធ្វើចិត្តឲ្យបរិសុទ្ធ ដោយអរហត្តផល នេះជាពាក្យទូន្មានជាឱវាទជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ដោយប្រការដូច្នេះ។

# គាថាទី២

**ខន្តិ បរមំ តបោ តីតិក្ខា**
**និព្វានំ បរមំ វទន្តិ ពុទ្ធា**
**ន ហិ បព្វជិតោ បរូបឃាតី**
**សមណោ ហោតិ បរំ វិហេឋយន្តោ។**

អំណត់ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថាព្រះនិព្វាន ជាគុណជាតដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិតមិនមែនជាសមណៈឡើយ ។

## បំភ្លឺគាថា

ធម្មបទអដ្ឋកថាពន្យល់ថាបទថា **ខន្តិ**(សេចក្តីអត់ធន់) សេចក្តីថាឈ្មោះថា ខន្តី ពោលគឺសេចក្តីអត់ធន់ឯណា ជាតបៈធម៌ដ៏ឧត្តមគឺប្រសើរខ្ពង់ខ្ពស់ក្នុងព្រះពុទ្ធសាសនា នេះ។

សុមង្គលវិលាសិនី ពន្យល់ថាបទថា **ខន្តី បរមំ តបោ** សេចក្តីថា**ខន្តី**គឺសេចក្តីអត់ធន់ជាតបៈធម៌ ដ៏ក្រៃលែង។ **តីតិក្ខា** (សេចក្តីអត់ធន់)ជាវេវចនៈ(ពាក្យប្រើជំនួសគ្នា)របស់ពាក្យថា **ខន្តី** នោះឯង។

អធិប្បាយថា **អធិវាសនក្ខន្តី**ពោលគឺសេចក្តីអត់ធន់យ៉ាងក្រៃលែង។

សារត្ថទីបនីដីកា ពន្យល់ថាក្នុងបទ**ខន្តី បរមំ** ជាដើម ឈ្មោះថា**ខន្តី** ព្រោះអត្ថថាអត់ធន់ គឺអត់សង្កត់នូវពាក្យអាក្រក់របស់បុគ្គលដទៃ គឺអត់ធន់ចំពោះអំពើអាក្រក់របស់បុគ្គលដទៃ និងធម្មជាតិដែលបិទបាំងនូវសេចក្តីល្អដែលផ្សេងដោយត្រជាក់ និងក្តៅជាដើម។ក៏**ខន្តី**នោះឈ្មោះថាជាតបៈធម៌ដ៏ក្រៃលែងគឺខ្ពង់ខ្ពស់ ព្រោះដុតបំផ្លាញគឺដុតកម្តៅកម្ចាត់ធម៌ដែលជាបដិបក្ខ ចំពោះគុណទាំងឡាយមានសីលជាដើមយ៉ាងវិសេស។ សេចក្តីអត់សង្កត់ គឺអត់ធន់

ឈ្មោះថា **តីតិក្ខា**។ ក៏ពាក្យថា **តីតិក្ខា** នេះ ជាវេវចនៈរបស់ **ខន្តី**នោះឯង។

ចំណែកវេយ្យាករណបណ្ឌិតទាំងឡាយតែងពណ៌នា**តីតិក្ខា** សព្ទក្នុងសេចក្ដីថា អត់ធន់ ព្រោះដូច្នោះបណ្ឌិតគប្បីឃើញសេចក្ដីក្នុងខនេះ យ៉ាងនេះថា ឈ្មោះថា **អធិវាសនក្ខន្តី** ពោលគឺ **តីតិក្ខា** ជាតបៈធម៌ដ៏ឧត្ដម។

ធម្មបទអដ្ឋកថាៈ បាទព្រះគាថា **និព្វានំ បរមំ វទន្តិ ពុទ្ធា** (ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតិដ៏ឧត្ដម)សេចក្ដីថា ពុទ្ធបុគ្គល ៣ ពួកនេះ គឺព្រះពុទ្ធទាំងឡាយ១ ព្រះបច្ចេកពុទ្ធទាំងឡាយ១ ព្រះអនុពុទ្ធទាំងឡាយ១ តែងពោលថាព្រះនិព្វាន ជាគុណជាតដ៏ឧត្ដម។**សុមង្គលវិលាសិនីៈ**បទថា **និព្វានំ បរមំ** (ព្រះនិព្វានជាគុណជាតិដ៏ឧត្ដម)សេចក្ដីថាព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ថាព្រះនិព្វានជាធម៌ដ៏ឧត្ដមដោយប្រការទាំងពួង

សារត្ថទីបនីដីកាបាទគាថា ថា **និព្វានំ បរមំ វតន្តិ ពុទ្ធា** មានសេចក្ដីថា ធម្មជាតចេញចាកតណ្ហា ដែលដល់នូវការរាប់ថា **វាន:** ព្រោះអត្ថថាដោតក្រង គឺបិទបាំងទុកព្រមនូវភពដទៃដោយភព ដោយភាវៈដែលជាតវនិកន្តិ ឬព្រោះអត្ថថាដោតក្រង គឺបិទបាំងទុកព្រមនូវកម្ម និងដោយផល ព្រោះពួកសត្វដែលនូវមានតណ្ហាប៉ុណ្ណោះ នឹងជាអ្នកមានភពថ្មីតទៅ។ ឈ្មោះថា **និព្វាន** ព្រោះតណ្ហានោះមិនមានដោយប្រការទាំងពួងក្នុងព្រះនិព្វាននោះ។ ក៏ព្រះពុទ្ធទាំងឡាយរមែងត្រាស់ថានិព្វាននោះប្រសើរក្រៃលែងដោយអាការៈទាំងពួងមានស្ងប់ប្រណីត ល្អិត គួរសេព និងជាដែនដ៏ក្សេមជាដើម។

**ធម្មបទអដ្ឋកថា** បទថា **ន ហិ បព្វជិតោ** (មិនមែនជាបព្វជិតទេ) សេចក្ដីថាបុគ្គលដែលចូលទៅ បៀតបៀននូវសត្វដទៃដោយគ្រឿងប្រហារទាំងឡាយមានបាតដៃជាដើម ឈ្មោះថាជាអ្នកបៀតបៀននូវសត្វដទៃមិនឈ្មោះថាជាបព្វជិតទេ

សុមង្គលវិលាសិនី:បទថា **ន ហិ បព្វជិតោ បរូបឃាតី** (អ្នកដែលចូលទៅសម្លាប់សត្វដទៃមិនមែនជាបព្វជិតទេ) សេចក្ដីថា អ្នកណាចូលទៅប្រទូសរ៉ាយរុកកួន និងបៀតបៀនអ្នកដទៃព្រោះមិនមាននូវ**អធិវាសនក្ខន្តិ** អ្នកនោះមិនឈ្មោះ ថាជាបព្វជិតទេ។

**សារត្ថទីបនីដីកា**:បាទគាថា **ន ហិ បព្វជិតោ បរូបឃាតី** គឺមានសេចក្ដីថា បុគ្គលដែលចូលទៅប្រហារ គឺបៀតបៀនធ្វើឲ្យអ្នកដទៃលំបាកព្រោះភាពជាអ្នកប្រាសចាក**អធិវាសនក្ខន្តិ** បុគ្គលនោះមិនឈ្មោះថាបព្វជិតទេ ព្រោះមិនបណ្ដេញនូវធម៌ ដែលគួរនឹងបណ្ដេញឲ្យចេញទៅ។ ចំណែកបាទទី៤ជាវេវចនៈរបស់បាទទី៣ នោះឯងព្រោះមិនមានសេចក្ដីដទៃទៀត។ ក៏បទថា **ន សមណោ ហោតិ** ជាវេវចនៈរបស់បទថា **ន ហិ បព្វជិតោ** នេះ។

បទថា **បរំ វិហេឋយន្តោ** ជាវេវចនៈរបស់បទថា**បរូបឃាតី**

នេះ។ ន័យម្យ៉ាងទៀត បទថា **បរូបឃាតី** ប្រែថា អ្នកចូលទៅទម្លាយសីល។ មែនពិតសីលលោកហៅថា **បរ** ព្រោះអត្ថថាប្រសើរ ព្រោះ **បរ** សព្ទ ប្រាប់សេចក្តីថាប្រសើរបំផុត ដូចក្នុងពាក្យថា **បុគ្គលបរោបរញ្ញូ**ប្រែថាអ្នកដឹងនូវភាពប្រសើរនិងមិនប្រសើរនៃបុគ្គលជាដើម។ ក៏សមណៈណាបៀតបៀនសត្វដទៃ រមែងឈ្មោះថា **បរូបឃាតី** គឺធ្វើសីលរបស់ខ្លួនឲ្យវិនាស អ្នកនោះមិនឈ្មោះថាជាបព្វជិតទេ។

ន័យមួយទៀត អ្នកណាអ្នកឈ្មោះថា **បរូបឃាតី** ព្រោះការមិនមាន **អធិវាសនក្ខន្តី**(ខន្តីយ៉ាងឧក្រិដ្ឋ ខន្តីដ៏មានកម្លាំង)រមែងដាក់ចុះនូវជីវិតអ្នកដទៃដោយហោចទៅសូម្បីសត្វរបោម មូស អ្នកនោះក៏មិនឈ្មោះថាជាបព្វជិតដែរ។ ព្រោះហេតុអ្វី? ព្រោះមិនបណ្តេញចេញ គឺមិនចេញនូវមន្ទិលដ៏លាមក មែនពិតពាក្យនេះថាបុគ្គលដែលលោក

ហៅថាបព្វជិត ព្រោះនាំចេញនូវមន្ទិលរបស់ខ្លួន នេះជាលក្ខណៈរបស់បព្វជិត សូម្បីបុគ្គលណាមិនបៀតបៀនគឺមិនសម្លាប់ តែធ្វើឲ្យគេលំបាកដោយដំបងជាដើម សូម្បីអ្នកនោះក៏មិនឈ្មោះថាជាសមណៈដែរ។ ព្រោះហេតុអ្វី? ព្រោះមិនរម្ងាប់ចាកការបៀតបៀន។

ប្រការមួយទៀត ព្រះដ៏មានព្រះភាគកាលនឹងទ្រង់សម្តែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ទើបត្រាស់ថា **ខន្តី បរមំ តបោ**ដូច្នេះជាខាងដើមដើម្បីនឹងសម្តែងវិធីទប់ស្កាត់ទោសៈនោះព្រោះសេចក្តីដែលកថាពោលដោយ

បាតិមោក្ខមានសីលជាប្រធាននិងព្រោះទោសៈជាបដិបក្ខដោយវិសេសចំពោះសីល។ ដោយពាក្យនោះទើបព្រះមានព្រះភាគត្រាស់ដល់ឧបាយកម្ចាត់អារម្មណ៍ដែលមិនគប្បីប្រាថ្នា ចំណែកដោយសព្វថា **តីតិក្ខា** ត្រាស់ដល់ ឧបាយកម្ចាត់អារម្មណ៍ដែលគប្បីប្រាថ្នា លោកសម្តែងសេចក្តីនៃ ខ នេះទុកថាបុគ្គលរមែងគ្របសង្កត់នូវសេចក្តីមិនត្រេកអរ

ដែលកើតឡើង និងសេចក្តីត្រេកអរ ដែលកើតឡើងដោយអារម្មណ៍ទាំងពីរយ៉ាងនោះ។ ព្រះពុទ្ធទាំងឡាយតែងត្រាស់ថា ព្រះនិព្វានជាធម៌ដ៏ឧត្តមព្រោះចូលទៅស្ងប់នូវវានៈ គឺតណ្ហាបាន។ បណ្តាពាក្យទាំងនោះ ទ្រង់សម្តែងការអត់សង្កត់ចំពោះទោសកំហុសរបស់អ្នកដទៃដោយសព្ទថា **ខន្តិ**។ទ្រង់សម្តែងការមិនខុសក្នុងអ្នកដទៃ ដោយសព្ទថា **តីតិក្ខា។** កាលព្រះមានព្រះភាគ ទ្រង់សម្តែងបាតិមោក្ខដោយអនុលោមតាមមាតិកានៃហេតុយ៉ាងនេះ ហើយឥឡូវនេះទ្រង់ប្រាថ្នានឹងសម្តែងបាតិមោក្ខនោះដោយពិសេសទើបទ្រង់ត្រាស់ពាក្យថា **ន ហិ** ជាដើម។

ដោយពាក្យនោះព្រះដ៏មានព្រះភាគ សម្តែងថា ការផ្តាច់បង់នូវជីវិតសត្វទាំងឡាយ និងការបៀតបៀនសត្វដទៃដោយបាតដៃ ដុំដីនិង ដំបងជាដើម ហៅថា **បរូបឃាតោ បរំ វិហេឋនំ** ការចូលទៅប្រហារសត្វដទៃ ៥ នេះ

យ៉ាងណា ការលួចទ្រព្យរបស់សត្វទាំងឡាយនោះ ការប្រព្រឹត្តិខុសក្នុងប្រពន្ធអ្នកដទៃ ការញុះញង់ឲ្យបែកគ្នានឹងគ្នា ការពោលពាក្យទ្រគោះបោះបោក ការនិយាយពាក្យរោយរាយឥតប្រយោជន៍ ការសំឡឹងរំពៃទ្រព្យអ្នកដទៃ សេចក្តីយល់ថាសត្វស្លាប់ហើយសូន្យនឹងការយល់ឃើញខុស ក៏រមែងជាការចូលទៅប្រហារ និងជាការបៀតបៀនសត្វដទៃយ៉ាងនោះដែរ ព្រោះដូច្នោះទើបមិនឈ្មោះថាជាបព្វជិត និងជាសមណៈ ដោយការធ្វើអកុសលកម្មបថ និងអកុសលកម្មយ៉ាងណាមួយ។

**ធម្មបទអដ្ឋកថាបទថា ន សមណោ** (មិនមែនជាសមណៈ) សេចក្តីថាបុគ្គលដែលនូវមានការបៀតបៀននូវសត្វដទៃតាមន័យដែលបានពោលហើយនោះ ក៏មិនឈ្មោះថាជាសមណៈដែរ។

**សុមង្គលវិលាសិនី:**បទថា **ន សមណោ ហោតិ** (មិនមែនជាសមណៈ) ជាវេវចនៈរបស់ពាក្យនេះថា **ន ហិបព្វជិតោ**

(មិនមែនជាបព្វជិត)។

បទថា **បរំ វិហេឋយន្តោ**(បៀតបៀនសត្វដទៃ) ជាវេវចនៈរបស់ពាក្យថា **បរូបឃាតី** (សម្លាប់សត្វដទៃ)។ម្យ៉ាងទៀត ពាក្យថា **បរូបឃាតី** គឺទ្រុស្តសីល។ ព្រោះសីលទ្រង់ត្រាស់ថា **បរំ** ដោយអត្ថថាឧត្តម ខ្ពង់ខ្ពស់។ អធិប្បាយថា ក៏សមណៈណាបៀតបៀននូវសត្វដទៃណាមួយ បានឈ្មោះថា ចូលទៅបៀតបៀនអ្នកដទៃ គឺធ្វើសីលរបស់ខ្លួនឲ្យវិនាសអ្នកនោះមិនឈ្មោះថាជាបព្វជិតទេ។

ម្យ៉ាងទៀតអ្នកណាចូលទៅប្រទូសរ៉ាយអ្នកដទៃព្រោះមិនមាន **អធិវាសនក្ខន្តិ** សម្លាប់សត្វដទៃដោយហោចទៅសូម្បីតែសត្វរបោម និងមូស អ្នកនោះក៏មិនឈ្មោះថា ជាបព្វជិតដែរ។ ព្រោះហេតុអ្វី? ព្រោះមិនទាន់លះនូវមន្ទិលបាន។ដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាអ្នកដែលបណ្តេញមន្ទិលរបស់ខ្លួនបានហេតុនោះទើបតថាគតហៅថាជាបព្វជិតដូច្នេះ នេះគឺជាលក្ខណៈរបស់បព្វជិត។

សូម្បីអ្នកណាមិនប្រទូសរ៉ាយ មិនសម្លាប់តែនៅបៀតបៀនដោយអាជ្ញាមានដំបងជាដើម អ្នកនោះក៏នៅតែបៀតបៀនអ្នកដទៃដដែល មិនឈ្មោះថាជាសមណៈទ្បើយ។ព្រោះហេតុអ្វី?ព្រោះមិនស្ងប់ចាកការបៀតបៀន។ ដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា អ្នកដែលតថាគតហៅថា សមណៈព្រោះស្ងប់ចាកបាប ដូច្នេះ នេះគឺជាលក្ខណៈរបស់សមណៈ។

# គាថាទី៣

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនតិះដៀល(អ្នកដទៃ)១ កិរិយាមិនបៀតបៀន(អ្នកដទៃ)១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់១ ការព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះជាពាក្យប្រៀនប្រដៅ នៃព្រះពុទ្ធទាំងឡាយ ។

## បំភ្លឺគាថា

ធម្មបទអដ្ឋកថា ពន្យល់ថាៈ **អនូបវាទោតិ អនូបវាទនញ្ចេវ អនូបវាទាបនញ្ច** ។ការមិនពោលតិះដៀលដោយខ្លួនឯង និងការមិនប្រើអ្នកដទៃឲ្យតិះដៀល ឈ្មោះថា **អនូបវាទោ** (កិរិយាមិនតិះដៀល)។

ការមិនបៀតបៀនដោយខ្លួនឯងនិងការមិនប្រើអ្នកដទៃឲ្យបៀតបៀនឈ្មោះថា**អនូបឃាតោ**(កិរិយាមិនបៀតបៀន)

**សុមង្គលវិលាសិនី:**បទថា **អនូបវាទោ** គឺមិនចូលទៅពោលតិះដៀលនូវបុគ្គលណាមួយដោយវាចា។

បទថា**អនូបឃាតោ**គឺមិនចូលទៅបៀតបៀនដោយកាយ។

**សារត្ថទីបនីដីកា:** ពន្យល់ថាៈបទថា **អនូបវាទោ** បានដល់ការមិនចូលទៅតិះដៀលអ្នកដទៃណាមួយដោយវាចា។ បទថា **អនូបឃាតោ** សេចក្តីថាការមិនធ្វើនូវការចូលទៅបៀតបៀនអ្នកណាមួយដោយកាយ និងចិត្ត ព្រោះការធ្វើនូវការចូលទៅបៀតបៀនទាក់ទងនឹងការគិតដល់សេចក្តីវិនាសជាដើម ដល់បុគ្គលដទៃសូម្បីដោយចិត្ត ក៏ជាប្រការដែលគួរវៀរដែរ។

**ធម្មបទអដ្ឋកថា** បទថា **បាតិមោក្ខេ** (ក្នុងបាតិមោក្ខ)បានដល់សីលដែលជាប្រធាន។ ការបិទបាំងឈ្មោះថា **សំវរ:** ប្រែ

ថាការសង្រួម។ ភាពនៃបុគ្គលជាអ្នកដឹងនូវប្រមាណ ពោលគឺការស្គាល់ប្រមាណ ឈ្មោះថា **មត្តញ្ញុតា**(ភាពជាអ្នកដឹងនូវប្រមាណ)

**សុមង្គលវិលាសិនី: បាតិមោក្ខេ** ញែកសព្ទ **ប+អតិ+មោក្ខំ** ប្រែថាការរួចផុតក្រៃលែង គឺសីលខ្ពស់បំផុត រមែងរក្សាដោយសេចក្ដីវិសេស គឺទៅកាន់សុគតិនិងឲ្យរួចចាកភ័យ គឺទុគ្គតិ ឬរមែងរក្សាសុគតិឲ្យផុតទុគ្គតិព្រោះដូច្នោះទើបលោកហៅសីលនោះថា **បាតិមោក្ខំ** អ្នកសង្រួមក្នុងបាតិមោក្ខនោះ។ បទថា **មត្តញ្ញុតា** (ភាពជាអ្នកដឹងប្រមាណ) គឺដឹងប្រមាណដោយអំណាចនៃការទទួល និងការបរិភោគ។

**សារត្ថទីបនីដីកាបទថា បាតិមោក្ខេ** សេចក្ដីថា សីលនោះឯណាដែលឈ្មោះថា**បាតិមោក្ខំ** ដែលប្រែថាជាប្រធាន គឺខ្ពង់ខ្ពស់លោកហៅថា **បាតិមោក្ខ** ព្រោះរក្សា គឺធ្វើឲ្យរួចផុត

ពីភ័យក្នុងសុគតិ និងភ័យទាំងឡាយក្នុងទុគ្គតិ ឬព្រោះអត្ថថាញ៉ាំងអ្នករក្សាសីលឲ្យផុតបាន ក្នុងសីលដែលឈ្មោះថា បាតិមោក្ខនោះផង។ បទថា **សំវរោ** បានដល់ ការសង្រួមដែលមានលក្ខណៈមិនល្មើសនូវ អាបត្តិទាំង ៧ កង។ បទថា **មត្តញ្ញុតា** បានដល់ភាពជាអ្នកដឹងប្រមាណក្នុងភោជនគឺដឹងប្រមាណក្នុងការទទួលនិងការបរិភោគ។ **ធម្មបទអដ្ឋកថា** ពន្យល់បទថា **បន្តំ** ប្រែថាដ៏ស្ងាត់ គឺទីដែលស្ងាត់ហើយ។ បទថា **អធិចិត្តេ** (ក្នុងអធិចិត្ត)សេចក្តីថាក្នុងចិត្តដ៏ក្រៃលែង ពោលគឺចិត្តដែលសហគតៈ(ប្រកប)ដោយសមាបត្តិ៨។ការធ្វើនូវសេចក្តីព្យាយាម ឈ្មោះថា **អាយោគោ** (សេចក្តីប្រកបព្យាយាម)។

**សុមង្គលវិលាសិនី:**ពន្យល់បទថា**បន្តញ្ច សយនាសនំ**(ទីដេកនិងទីអង្គុយដ៏ស្ងាត់) សេចក្តីថាវាចាកការជ្រៀតបៀននូវទីដេកនិងទីអង្គុយ។ ក្នុងបទនោះគប្បីជ្រាបថា គឺលោក

ពោលដល់សេចក្តីសន្តោសក្នុងបច្ច័យ៤ ដោយបច្ច័យតែ២ប៉ុណ្ណោះ។

សារត្ថទីបនីដីកា:បទថា **បន្តញ្ច សយនាសនំ** ប្រែថា នឹងសេនាសនៈដែលប្រាសចាកការច្របូកច្របល់ដោយមិនមានទីចង្អៀតគឺគណៈដែលស្ងាត់ហើយ។

បទថា **អធិចិត្តេ ច អាយោគោ** (កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត)មានសេចក្តីថា ចិត្តក្នុងសមាបត្តិ៨ ដែលជាបាទនៃវិបស្សនា ឈ្មោះថា **អធិចិត្ត** និងសូម្បីតអំពីនោះ មគ្គចិត្ត និងផលចិត្តនោះឯងក៏ឈ្មោះថា **អធិចិត្ត** ការប្រកប គឺការព្យាយាមក្នុងអធិចិត្ត តាមដែលពោលហើយនោះឯង ។

**សុមង្គលវិលាសិនី:** បទថា **ឯតំ ពុទ្ធាន សាសនំ** សេចក្តីថា ការមិនចូលទៅតិះដៀល មិនបៀតបៀនអ្នកដទៃ ការសង្រួមក្នុងបាតិមោក្ខ ភាពជាអ្នកស្គាល់ប្រមាណក្នុងការទទួល និងបរិភោគ ការអាស្រ័យនៅទីសេនាសនៈដ៏ស្ងាត់

ព្រោះជាអ្នកជំនាញក្នុងសមាបត្តិ៨ នេះជាពាក្យទូន្មានជាឱវាទ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ។ គប្បីជ្រាបថា គាថាទាំងនេះជាការសម្តែងបាតិមោក្ខទ្វេសរបស់ព្រះពុទ្ធទាំងឡាយ។

សារត្ថទីបនីដីកាបទថាៈ **ឯតំ ពុទ្ធាន សាសនំ** សេចក្តីថា ការមិនតិះដៀលអ្នកដទៃ១ ការមិនបៀតបៀនអ្នកដទៃ១ ភាពជាអ្នកដឹងប្រមាណក្នុងការទទួល និងការបរិភោគ១ ការសេពទីដេក និងទីអង្គុយដ៏ស្ងាត់១ ការប្រកបរឿយៗក្នុងអធិចិត្ត១ នេះជាពាក្យទូន្មានជាឱវាទជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ។

ព្រះបរមពុទ្ធោវាទ៣ គាថានេះឈ្មោះថាឱវាទបាតិមោក្ខ ជាព្រះឱវាទ មានសេចក្តីវិសេស ១១ ប្រការដូចន័យដែលចែកជាកណ្ឌ ៗ តទៅនេះ គឺៈ

១- សព្វបាបស្ស អករណំ ការមិនធ្វើអំពើបាបទាំងពួង

២- កុសលស្សូបសម្បទា ការបំពេញកុសលឲ្យបរិបូណ៌

៣- សចិត្តបរិយោទបនំ ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ។

៤- ខន្តិ បរមំ តបោ តីតិក្ខា អធិវាសនខន្តីពោលគឺសេចក្តីអន់ធន់ជាតបៈធម៌ដ៏ឧត្តម

៥- និព្វានំ បរមំ វទន្តិ ពុទ្ធា ព្រះពុទ្ធទាំងឡាយតែងសម្តែងថាព្រះនិព្វានជាធម៌ឧត្តម

៦- ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ បុគ្គលដែលសម្លាប់សត្វដទៃមិនឈ្មោះថាបព្វជិត បុគ្គលដែលបៀតបៀនសត្វដទៃមិនឈ្មោះថាសមណៈទ្បើយ

៧- អនូបវាទោ អនូបឃាតោ ការមិនពោលតិះដៀល ( អ្នកដទៃ ) ការមិនបៀតបៀន(អ្នកដទៃ )

៨- បាតិមោក្ខេ ច សំវរោ ការសង្រួមក្នុងបាតិមោក្ខ

៩- មត្តញ្ញុតា ច ភត្តស្មឹ ភាវៈជាអ្នកដឹងប្រមាណក្នុងភត្ត

១០- បន្តញ្ច សយនាសនំ ទីដេកទីអង្គុយដ៏ស្ងាត់

១១- អធិចិត្តេ ច អាយោគោ ការបំពេញព្យាយាមក្នុងអធិចិត្ត។នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ។

ឱវាទបាតិមោក្ខនេះជាសាសនធម៌ផ្លូវប្រតិបត្តិរបស់ពុទ្ធបរិស័ទគ្រប់ចំពូកទូទៅទាំងពុទ្ធសាសនមណ្ឌល។ ធម្មតាព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលបានត្រាស់ដឹងក្នុងអតីតកាលកន្លងហើយ តាំងពីព្រះវិបស្សីសម្មាសម្ពុទ្ធជាដើមក្តី ព្រះអរហន្តសម្មាសម្ពុទ្ធដែលនឹងបានត្រាស់ក្នុងអនាគតកាលខាងមុខក្តី ព្រះអរហន្តសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើងទាំងឡាយដែលមានសាសនោវាទ រុងរឿងនៅសព្វថ្ងៃនេះក្តី ព្រះសម្មាសម្ពុទ្ធក្នុងកាលទាំង ៣ តែងទ្រង់ធ្វើវិសុទ្ធិឧបោសថសម្តែងឱវាទបាតិមោក្ខ ៣ គាថានេះ ក្នុងទីប្រជុំនៃព្រះសង្ឃសាវ័កដ៏ប្រសើរដែល ហៅថាចតុរង្គសន្និបាត (ការប្រជុំសាវ័កប្រកបដោយអង្គ ៤) ដូចគ្នាគ្រប់ៗអង្គផ្សេងតែវារៈដែលទ្រង់សម្តែងព្រះអង្គខ្លះច្រើនដងព្រះអង្គខ្លះតិចដងនិង ផ្សេងចំនួនភិក្ខុដែលមកប្រជុំ

ច្រើនតិច ជាងគ្នាតាមកាលតែប៉ុណ្ណោះ។

## ៣ ទ្រង់ដាក់អាយុសង្ខារ

### ទ្រង់យាងចូលសម្រាកនៅឯបាវាលចេតិយ

សម័យមួយព្រះដ៏មានព្រះភាគកាលគង់ក្នុងកូដាគារសាលានាមហាវ៉នជិតក្រុងវេសាលី។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងវេសាលីដើម្បីបិណ្ឌបាត។ លុះទ្រង់ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងវេសាលី ហើយទ្រង់ត្រឡប់អំពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្ត ហើយទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទចូរអ្នកកាន់យកនិសីទនៈទៅ យើងនឹងចូលទៅសម្រាកក្នុងវេលាថ្ងៃឯបាវាលចេតិយ។ ព្រះអានន្ទដ៏មានអាយុបានទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គហើយក៏កាន់និសីទនៈទៅតាមខាងក្រោយ

ព្រះដ៏មានព្រះភាគទៅ។ គ្រានោះព្រះដ៏មានព្រះភាគកាលស្ដេចចូលទៅកាន់បាវាលចេតិយ លុះចូលទៅដល់ហើយក៏គង់លើអាសនៈដែលព្រះអានន្ទក្រាលថ្វាយ។ លុះព្រះដ៏មានព្រះភាគគង់ហើយ ក៏ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទក្រុងវេសាលីជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ។ ម្នាលអានន្ទឥទ្ធិបាទទាំង៤ បើបុគ្គលណាមួយបានចំរើនហើយ បានធ្វើឲ្យច្រើនបានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់បានប្រព្រឹត្តរឿយៗបានសន្សំទុកបានប្រារព្ធល្អហើយ ម្នាលអានន្ទ បុគ្គលនោះទោះបីប្រាថ្នានឹងគប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន (១អាយុកប្បក្នុងទីនេះគឺ១00ឆ្នាំ)។ ម្នាលអានន្ទឯឥទ្ធិបាទទាំង ៤ តថាគតបានចំរើនហើយ បានធ្វើ

ឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បាន ប្រព្រឹត្តរឿយៗ បានសន្សំទុកបានប្រារព្ធល្អហើយ ម្នាល អានន្ទ តថាគតបើប្រាថ្នាគប្បីឋិតនៅអស់ ១ អាយុកប្ប ឬ លើសជាង ១ អាយុកប្បក៏បាន។ ឯព្រះអានន្ទដ៏មានអាយុ ទុកជាព្រះដ៏មានព្រះភាគទ្រង់ធ្វើនិមិត្តជាឱឡារិកទ្រង់ធ្វើ ឱភាសជាឱឡារិកយ៉ាងនេះហើយក៏មិនអាចនឹងយល់ សេចក្តីច្បាស់លាស់បាន មិនបានអារាធនាព្រះដ៏មានព្រះ ភាគថា បពិត្រព្រះអង្គដ៏ចំរើនសូមព្រះដ៏មានព្រះភាគឋិត នៅអស់ ១ អាយុកប្ប បពិត្រព្រះអង្គដ៏ចំរើន សូមព្រះ សុគតឋិតនៅអស់១អាយុកប្ប ដើម្បីប្រយោជន៍ដល់ជន ច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់ សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ដើម្បី សេចក្តីសុខដល់ពួកទេវតា និងមនុស្សដូច្នេះសោះ ព្រោះ មារចូលមកជ្រែកគំនិត។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះ ពុទ្ធដីកាជាគំរប់ ២ ដងផង។ ព្រះដ៏មានព្រះភាគ ទ្រង់មាន

ព្រះពុទ្ធដីកានឹងព្រះអានន្ទដ៏មានអាយុជាគំរប់ ៣ ដងផង ឯព្រះអានន្ទដ៏មានអាយុទុកជាព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិកទ្រង់ធ្វើឱភាសជាឱឡារិកយ៉ាងនេះ ហើយក៏មិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនបានអារាធនាព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគឋិតនៅអស់១អាយុកប្ប ឬលើសជាង ១ អាយុកប្បនោះទេព្រោះមារចូលមកជ្រែកគំនិត។ លំដាប់នោះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅចុះអ្នកចូរសំគាល់នូវកាលដែលគួរនឹងទៅក្នុងកាលឥឡូវនេះចុះ។ ព្រះអានន្ទដ៏មានអាយុបានទទួលព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ រួចក៏ក្រោកចាកអាសនៈហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណរួចអង្គុយទៀបគល់ឈើមួយ ជិតព្រះដ៏មានព្រះភាគ។




## មារមានចិត្តបាបចូលទៅអារាធនាព្រះដ៏មានព្រះភាគចូលបរិនិព្វាន

គ្រានោះកាលបើព្រះអានន្ទដ៏មានអាយុចៀសចេញទៅមិនយូរប៉ុន្មាន មារមានចិត្តបាបក៏បានពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថាបពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគបរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចំរើនឥឡូវនេះជាកាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះ

អង្គដ៏ចំរើន ព្រោះថាព្រះដ៏មានព្រះភាគបានត្រាស់វាចានេះហើយថា នៃមារមានចិត្តបាបពួកភិក្ខុជាសាវ័ករបស់តថាគតដែលឈ្លាសវាងវៃ ក្លៀវក្លា ដល់នូវការក្សេម ចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ បានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួនហើយ ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើកចែកធ្វើឲ្យងាយបានបានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនបានសង្កត់សង្កិនដោយល្អតាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យនៅមិនទាន់មានដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះដូច្នេះ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះពួកភិក្ខុជាសាវ័ករបស់ព្រះដ៏មានព្រះភាគបានឈ្លាសវៃក្លៀវក្លាដល់នូវការក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ទាំងបានរៀននូវវាទៈ

នៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើកចែកធ្វើឲ្យងាយបានហើយទាំងសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយឲ្យជាកិច្ចដែលបានសង្កត់សង្កិន ដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ ប្រកបដោយបាដិហារ្យបានហើយ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះសូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះ សុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះជា កាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រោះព្រះដ៏មានព្រះភាគត្រាស់វាចា នេះហើយថា ម្នាលមារមានចិត្តបាប ពួកភិក្ខុនីជាសាវិកា របស់តថាគតមិនទាន់មានដរាបណា តថាគតនឹងមិន ទាន់បរិនិព្វានដរាបនោះ។ ពួកឧបាសកជាសាវ័ក របស់ តថាគតមិនទាន់មានដរាបណា។ពួកឧបាសិកាជាសាវិកា របស់តថាគតនៅមិនទាន់មានដរាបណាទេ តថាគតនឹង មិនទាន់បរិនិព្វានដរាបនោះ។ បពិត្រព្រះអង្គដ៏ចំរើនឥឡូវ

នេះ ពួកភិក្ខុនីជាសាវិកា ពួកឧបាសកជាសាវ័ក ពួកឧបាសិកាជាសាវិការបស់ព្រះដ៏មានព្រះភាគដែលឈ្លាសវាងវៃ ក្លៀវក្លា ដល់នូវការក្សេម ចាកយោគៈ ជាពហុស្សូតទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរប្រព្រឹត្តតាមធម៌ ទាំងបានរៀននូវវាទៈ នៃអាចារ្យរបស់ខ្លួនហើយ ប្រាប់សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុហើយ សំដែងធម៌ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះសូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចំរើនឥឡូវនេះជាកាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើនមួយទៀតព្រះដ៏មានព្រះភាគ បានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះនៅមិនទាន់

ខ្ជាប់ខ្ជួន មិនទាន់ចំរើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា និងមិនទាន់ពេញបរិបូណ៌ដរាបណាមួយទៀតពួកទេវតា និងមនុស្សមិនទាន់ចេះសំដែងបានដោយប្រពៃដរាបណាតថាគតនឹងមិនបរិនិព្វានដរាបនោះដូច្នេះ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រហ្មចារ្យរបស់ព្រះដ៏មានព្រះភាគនេះ បានខ្ជាប់ខ្ជួនហើយបានចំរើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតានិងមនុស្សចេះសំដែងបានដោយល្អហើយ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះជាកាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ។

**ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះការបរិនិព្វាន របស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយៗ** លំដាប់នោះ

ព្រះដ៏មានព្រះភាគ ទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារឰដ៏បាវាលចេតិយ។ លុះព្រះដ៏មានព្រះភាគទ្រង់ដាក់អាយុសង្ខារហើយ ក៏កើតការកក្រើកផែនដីយ៉ាងធំ គួរឲ្យភ្លូកភ្លឹកព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង។គ្រានោះព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយ ក៏បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

**តុលមតុលញ្ច សម្ភវំ ភវសង្ខារមវស្សជ្ជិ មុនិ អជ្ឈត្តរតោ សមាហិតោ អភិន្ទិ កវចមិវត្តសម្ភវន្តិ ។**

ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វាន ដែលមានគុណាថ្លឹងមិនបានផង នូវភពផង ទ្រង់លះបង់នូវសង្ខារដែលនាំសត្វទៅកាន់ភព ទ្រង់ត្រេកអរនូវអារម្មណ៍ខាងក្នុង (ដោយអំណាចវិបស្សនា) មានព្រះហឫទ័យតាំងមាំហើយ (ដោយអំណាចសមថៈ) ទ្រង់បានទំលាយនូវបណ្តាញ គឺកិលេស ដែលកើតមាននៅក្នុងព្រះអង្គដូចជាក្រោះ។

# ហេតុនៃការកក្រើកផែនដី៨យ៉ាង

លំដាប់នោះ ព្រះអានន្ទដ៏មានអាយុមានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ការកក្រើកផែនដីនេះជាយ៉ាងធំ ការកក្រើកផែនដីនេះធំណាស់តើ គួរឲ្យភ្លូកភ្លឹកឲ្យព្រឺព្រួចរោមទាំងផ្គរក៏លាន់ឮឡើង។ ហេតុដូចម្តេច បច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យការកក្រើកផែនដី ជាយ៉ាងធំម្ល៉េះ។ ទើបព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ។ លុះព្រះអានន្ទដ៏មានអាយុគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ការកក្រើកផែនដីនេះជាយ៉ាងធំ បពិត្រព្រះអង្គដ៏ចំរើន ការកក្រើកផែនដីនេះធំពេកណាស់តើ គួរឲ្យភ្លូកភ្លឹក គួរឲ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង។ បពិត្រព្រះអង្គដ៏ចំរើន ហេតុដូចម្តេច បច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យកើតការកក្រើកផែនដីជា

យ៉ាងធំម្ល៉េះ? ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ហេតុបច្ច័យដែលនាំឲ្យកើតការកក្រើកផែនដីនេះមាន៨យ៉ាង។ ហេតុបច្ច័យទាំង ៨យ៉ាង តើដូចម្ដេចខ្លះ? ម្នាលអានន្ទ មហាប្រឋពីនេះប្រតិស្ឋាននៅលើទឹក ឯទឹកប្រតិស្ឋាននៅលើខ្យល់ ខ្យល់ប្រតិស្ឋាននៅលើអាកាស ម្នាលអានន្ទ សម័យដែលមានខ្យល់បក់ខ្យល់ធំដែលបក់នោះ រមែងធ្វើទឹកឲ្យកក្រើក ឯទឹកដែលកក្រើកមកហើយ ក៏ធ្វើផែនដីឲ្យកក្រើកដែរ ម្នាលអានន្ទ នេះជាហេតុជាបច្ច័យ ទី១ ដែលនាំឲ្យកើតការកក្រើកផែនដីជាយ៉ាងធំ។ម្នាលអានន្ទ មួយទៀតសមណៈក្ដី ព្រាហ្មណ៍ក្ដី ដែលមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញក្នុងចិត្ត ឬទេវតាដែលមានឫទ្ធិធំ មានអានុភាពធំ បុគ្គលនោះបានចំរើនបឋវីសញ្ញា ឲ្យមានកម្លាំងតិច ចំរើនអាបោសញ្ញាឲ្យមានកម្លាំងច្រើន បុគ្គលនោះ រមែងធ្វើផែនដីនេះឲ្យកក្រើករំពើករំភើបញ្ជាប់ញ័របាន ម្នាលអានន្ទនេះជាហេតុ ជាបច្ច័យ ទី២ ដែលនាំឲ្យ

កើតការកក្រើកផែនដីជាយ៉ាងធំ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វច្យុតចាកពួកទេវតាដែល ឋិតនៅក្នុងឋានតុសិត មានសតិ និងសម្បជញ្ញៈ យាងចុះ កាន់ព្រះមាតុឧទរ ក្នុងកាលនោះផែនដីនេះតែងកក្រើក រំពើករំភើបញាប់ញ័រ ម្នាលអានន្ទនេះជាហេតុ ជាបច្ច័យទី ៣ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ។ ម្នាលអានន្ទមួយ ទៀតកាលណាដែលពោធិសត្វ មានសតិនិងសម្បជញ្ញៈ ទ្រង់ប្រសូតចាកព្រះមាតុឧទរក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទនេះជាហេតុជា បច្ច័យ ទី៤ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ។ ម្នាល អានន្ទ មួយទៀតកាលណា ដែលព្រះតថាគតត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទនេះជាហេតុជា បច្ច័យ ទី៥ ដែលនាំឲ្យកើតការកក្រើកផែនដីជាយ៉ាងធំ។ ម្នាលអានន្ទ មួយទៀតកាលណាដែលព្រះតថាគតញុំាង

អនុត្តរធម្មចក្រ ឲ្យប្រព្រឹត្តទៅកាលនោះផែនដីនេះ តែង កក្រើករំភើបញ្ជាប់ញ័រ ម្នាលអានន្ទនេះជាហេតុជាបច្ច័យ ទី៦ ដែលនាំឲ្យកើតការកក្រើកផែនដីជាយ៉ាងធំ។ ម្នាល អានន្ទ មួយទៀតកាលណាដែលព្រះតថាគតមានសតិ និងសម្បជញ្ញៈដាក់ចុះនូវអាយុសង្ខារ ក្នុងកាលនោះផែន ដីនេះតែងកក្រើក រំភើបញ្ជាប់ញ័រ ម្នាលអានន្ទ នេះជា ហេតុជាបច្ច័យ ទី៧ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ។ ម្នាលអានន្ទ មួយទៀតកាលណាដែល ព្រះតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញ្ជាប់ញ័រ ម្នាលអានន្ទ នេះជាហេតុជាបច្ច័យ ទី៨ ដែលនាំឲ្យការកក្រើកផែនដី ជាយ៉ាងធំ។ ម្នាលអានន្ទ ហេតុបច្ច័យដែលនាំឲ្យកើតការ កក្រើកផែនដីជាយ៉ាងធំ មាន ៨ យ៉ាងនេះឯង។

លោកពោលទុកក្នុងមហាបទានសូត្រថា ក្នុងហេតុផែនដីញ័រ នេះ៨ប្រការដូចពោលមកនេះ ទី១ ញ័រដោយធាតុកម្រើក

ទី២ ញ៉័រដោយអានុភាពរបស់អ្នកមានឫទ្ធិ ទី ៣ និងទី ៤ ញ៉័រដោយតេជះនៃបុណ្យ ទី ៥ ញ៉័រដោយអំណាចញាណ ទី៦ ញ៉័រដោយអំណាចសាធុការ ទី ៧ ញ៉័រដោយអំណាចភាពជាអ្នកមានករុណា ទី ៨ ញ៉័រដោយការស្រែកយំ។ កាលព្រះមហាពោធិសត្វចុះកាន់ព្រះគភ៌ព្រះមាតា និងចេញអំពីព្រះគភ៌នោះ ផែនដីញ៉័រដោយអំណាចនៃបុណ្យរបស់ព្រះអង្គ។ គ្រាទ្រង់ត្រាស់ដឹងអភិសម្ពោធិញាណផែនដីញ៉័រដោយអំណាចព្រះញាណ។ គ្រាទ្រង់ត្រាស់ប្រកាសព្រះធម្មចក្រផែនដីក៏ញ៉័ររញ្ជួយឡើងឲ្យសាធុការ។ គ្រាព្រះមានព្រះភាគទ្រង់ដាក់អាយុសង្ខារ ផែនដីញ៉័ររញ្ជួយឡើងដោយសេចក្ដីករុណា ទ្រាំការកម្រើកញ៉័រនៃចិត្តមិនបាន ក៏ញាប់ញ៉័រ។ គ្រាបរិនិព្វានផែនដីក៏ត្រូវបន្ថែមដោយកម្លាំងការស្រែកយំក៏ញ៉័រ។ក៏សេចក្ដីនេះគប្បីជ្រាបដោយអំណាចទេវតាប្រចាំផែនដី។ តែប្រការនេះ មិនមានដល់បឋវីធាតុដែលជាមហាភូតរូប ព្រោះមិនមានចេតនានោះឯង។ នេះ

ជាការបង្ហាញសេចក្តីដែលទ្រង់សម្តែងមកហើយ។ ដោយហេតុត្រឹមតែប៉ុណ្ណេះព្រះអានន្ទកំណត់ថាព្រះមានព្រះភាគទ្រង់ដាក់អាយុសង្ខារថ្ងៃនេះពិតប្រាកដ។

## បរិសទ៍៨ពួក

ម្នាលអានន្ទ បរិសទ្យនេះមាន៨ ពួក។ បរិសទ្យទាំង ៨ពួកតើដូចម្តេច? គឺខត្តិយបរិសទ្យ ព្រាហ្មណបរិសទ្យ គហបតិបរិសទ្យ សមណបរិសទ្យចាតុម្មហារាជិកបរិសទ្យ តាវត្តិង្សបរិសទ្យ មារបរិសទ្យ ព្រហ្មបរិសទ្យ។ ម្នាលអានន្ទ ចំណែកតថាគត ចូលទៅកាន់ខត្តិយបរិសទ្យជាច្រើនរយ រមែងស្គាល់ច្បាស់។ តថាគត ចូលទៅកាន់ព្រាហ្មបរិសទ្យ ជាច្រើនរយ រមែងស្គាល់ច្បាស់។ គហបតិបរិសទ្យ។ សមណបរិសទ្យ ។ ចាតុម្មហារាជិកាបរិសទ្យ ។ តាវត្តិង្ស បរិសទ្យ ។ មារបរិសទ្យ ។បេ។ ព្រហ្មបរិសទ្យ ។ ក្នុងព្រហ្ម បរិសទ្យនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចា ជាមួយផង ធ្លាប់ចូលទៅសាកច្ឆាជាមួយផង។ សម្បុរ

របស់ព្រហ្មទាំងនោះ ក្នុងព្រហ្មបរិសទ្យនោះយ៉ាងណា សម្បុររបស់តថាគត ក៏យ៉ាងនោះដែរ សំឡេងរបស់ព្រហ្មទាំងនោះយ៉ាងណា សំឡេងរបស់តថាគត ក៏យ៉ាងនោះដែរ។ មួយទៀតតថាគតបានញ៉ាំងព្រហ្មទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាកាលដែលតថាគតកំពុងនិយាយ ចំណែកខាងព្រហ្មទាំងនោះ មិនស្គាល់តថាគតថា ជនដែលកំពុងនិយាយនេះជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ លុះតថាគតញ៉ាំងព្រហ្មទាំងនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយក៏បាត់រូបទៅ កាលដែលតថាគតបាត់រូបទៅហើយ ចំណែកព្រហ្មទាំងនោះនៅតែមិនស្គាល់តថាគតថាជនដែលបាត់ទៅហើយនេះ តើជាអ្វីហ្ន៎ ជាទេវតាឬជាមនុស្សដូច្នេះឡើយ ។ ម្នាលអានន្ទបរិសទ្យមាន ៨ ពួកនេះឯង ។

(ព្រះអង្គទ្រង់សម្តែងច្រើនទៀត មាន អភិភាយតនៈ៨ និង វិមោក្ខ ៨ជាដើមតែក្នុងសៀវភៅនេះខ្ញុំមិនបានរៀបរៀងទេ។ )

ម្នាលអានន្ទសម័យមួយតថាគតបានត្រាស់ជាដំបូង បានគង់នៅក្រោមដើមអជបាលនិគ្រោធ(ជ្រៃ)ក្បែរឆ្នេរស្ទឹង នេរញ្ជរាក្នុងឧរុវេលាប្រទេសឯណោះ។ ម្នាលអានន្ទ គ្រា នោះឯង ក្រុងមារមានចិត្តបាបចូលទៅរកតថាគត លុះ ចូលដល់ហើយបានឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះក្រុងមារមានចិត្តបាបឋិតនៅក្នុងទីដ៏សមគួរហើយ បាននិយាយយ៉ាងនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ ចំរើន ឥឡូវនេះសូមព្រះមានព្រះភាគបរិនិព្វានទៅ សូម ព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចំរើនឥឡូវនេះជា កាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ម្នាល អានន្ទ កាលបើក្រុងមារមានចិត្តបាបបាននិយាយយ៉ាង នេះហើយ តថាគតក៏បានពោលពាក្យនេះទៅនឹងក្រុងមារ មានចិត្តបាបថា ម្នាលមារមានចិត្តបាបពួកភិក្ខុជាសាវ័ក

របស់តថាគត ពួកភិក្ខុនីជាសាវិការបស់តថាគត។ពួកឧបាសក ជាសាវ័ករបស់តថាគត ពួកឧបាសិកា ជាសាវិការបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់បានរៀន នូវវាទៈនៃអាចារ្យរបស់ខ្លួនហើយប្រាប់សំដែង បញ្ញត្ត តាំងទុក បើកចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនបានដោយល្អតាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វានដរាបនោះ ។ ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះនៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា ទាំងមិនទាន់ពេញបរិបូណ៌ ដរាបណា មួយទៀតពួកទេវតា និងមនុស្សមិនទាន់ចេះសំដែង

បានដោយប្រពៃដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វាន ដរាបនោះ។ ម្នាលអានន្ទ ថ្ងៃនេះក្រុងមារមានចិត្តបាបបាន ចូលមករកតថាគតក្នុងបាវាលចេតិយ អម្បាញ់មិញនេះ ឯង បានឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះមារ មានចិត្តបាបបានឋិតនៅក្នុងទីដ៏សមគួរហើយក៏បាន ពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចរើន ឥឡូវនេះសូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះ សុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះជា កាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រ ព្រះអង្គដ៏ចំរើនព្រោះព្រះដ៏មានព្រះភាគ បានត្រាស់ព្រះ វាចានេះថា ម្នាលមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់ តថាគតនៅមិនទាន់មានដរាបណាទេ តថាគតក៏មិនទាន់ បរិនិព្វានដរាបនោះ។ ពួកភិក្ខុនីជាសាវិការបស់តថាគត នៅមិនទាន់មានដរាបណា។ ពួកឧបាសក ពួកឧបាសិកា ជាសាវ័ក ជាសាវិការបស់តថាគតនៅមិនទាន់មានដរាប

ណា។ ព្រហ្មចារ្យរបស់តថាគតនេះនៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា ទាំងមិនទាន់ពេញបរិបូណ៌ដរាបណា មួយទៀតពួកទេវតានិងមនុស្សមិនទាន់ចេះសំដែងបាន ដោយប្រពៃដរាបណា(តថាគតក៏មិនទាន់បរិនិព្វានដរាបនោះ) ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះព្រហ្មចារ្យរបស់ព្រះមានព្រះភាគបានខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតានិងមនុស្សចេះសំដែងបានដោយល្អហើយ ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះសូមព្រះមានព្រះភាគបរិនិព្វានទៅសូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ។ ម្នាលអានន្ទ កាលបើក្រុងមារបាននិយាយយ៉ាងនេះហើយ តថាគតក៏បានពោលពាក្យនេះទៅនឹងក្រុងមារមានចិត្តបាបថា **ម្នាលមារមាន**

ចិត្តបាប ចូរអ្នកមានសេចក្ដីខ្វល់ខ្វាយតិចចុះ ការបរិនិព្វាន របស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយម្នាលអានន្ទក្នុងថ្ងៃនេះតថាគត មានសតិសម្បជញ្ញៈ បានដាក់អាយុសង្ខារ ក្នុងបាវាលចេតិយអម្បាញ់មិញនេះឯង ។

## ព្រះអានន្ទទូលឃាត់អង្វរព្រះមានព្រះភាគសូមឲ្យព្រះអង្គគង់អស់ ១ អាយុកប្ប

កាលបើព្រះមានព្រះភាគមានពុទ្ធតម្រាស់ យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុក៏បានក្រាបបង្គំទូលឃាត់ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតឋិតនៅអស់ ១ អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដី

សុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអានន្ទ ឥឡូវនេះ កុំឡើយ អ្នកកុំអង្វរតថាគតឡើយ ម្នាលអានន្ទ ឥឡូវនេះ មិនមែនជាកាលគួរអារាធនាតថាគតទេ ។ ព្រះអានន្ទមានអាយុបានក្រាបបង្គំទូលជាគម្រប់ ២ ដងផង។ ព្រះអានន្ទមានអាយុបានក្រាបបង្គំទូល ព្រះមានព្រះភាគជាគម្រប់ ៣ ដងផង។ ម្នាលអានន្ទ អ្នកជឿពោធិញ្ញាណរបស់តថាគតដែរឬ ? បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿ ។ ម្នាលអានន្ទ កាលបើអ្នកជឿដែរ ហេតុអ្វីក៏អ្នកនៅតែទទូចតថាគតដល់ទៅ ៣ ដង ។ បពិត្រព្រះអង្គដ៏ចំរើនព្រះពុទ្ធដីកានេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្របានត្រងរង ក្នុងទីចំពោះព្រះភក្ត្រថា ម្នាលអានន្ទឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើរឿយៗហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះបើប្រាថ្នានឹងឋិត

នៅគប្បីឋិតនៅអស់១អាយុកប្ប ឬលើសជាង១អាយុកប្ប ក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបាន ចម្រើនហើយ បានធ្វើរឿយៗហើយ បានធ្វើឲ្យដូច ជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុក រឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អ ហើយ ម្នាលអានន្ទបើតថាគត ប្រាថ្នានឹងឋិតនៅ គប្បីឋិត នៅអស់១អាយុកប្បឬលើសជាង១អាយុកប្បក៏បាន។

ម្នាលអានន្ទ អ្នកជឿឬទេ ? បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះ អង្គជឿ ។ ម្នាលអានន្ទ ហេតុដូច្នោះ នេះជាអំពើទាស់របស់ អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ព្រោះតថាគត បានធ្វើនិមិត្តជាឱឡារិក បានធ្វើឱភាសជាឱឡារិកយ៉ាង នេះហើយ អ្នកនៅតែមិនយល់សេចក្តីច្បាស់លាស់បាន មិនអារាធនាតថាគតថា សូមព្រះដ៏មានព្រះភាគឋិតនៅ អស់១អាយុកប្ប សូមព្រះសុគតឋិតនៅអស់១អាយុកប្ប ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់

ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយដូច្នេះសោះ។ ម្នាលអានន្ទបើអ្នកអារាធនាតថាគត តថាគតគប្បីឃាត់វាចារបស់អ្នកត្រឹមតែ ២ លើក តែដល់ទៅ ៣ លើក តថាគតគប្បីទទួល ម្នាលអានន្ទ ព្រោះហេតុនោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

ម្នាលអានន្ទសម័យមួយតថាគតគង់នៅលើភ្នំគិជ្ឈកូដទៀបក្រុងរាជគ្រឹះឯណោះ។ ម្នាលអានន្ទ សម័យមួយតថាគតនៅក្នុងគោតមនិគ្រោធជិតក្រុងរាជគ្រឹះ។ តថាគតនៅជិតជ្រោះជាទីទម្លាក់នូវចោរទៀបក្រុងរាជគ្រឹះ។

តថាគត នៅក្នុងសត្តបណ្ណគុហា (គុហាដែលសន្ទតដោយដើមសត្បណ្ណព្រឹក្ស) ខាងភ្នំវេភារៈជិតក្រុងរាជគ្រឹះនោះ ។ តថាគតនៅក្នុងកាឡសិលា (ថ្មខ្មៅ) ខាងភ្នំឥសិគិលិទៀបក្រុងរាជគ្រឹះនោះ ។ តថាគតនៅក្នុងសប្បសោណ្ឌិកបព្ភារៈ

(ញកមានត្រពាំងទឹកជាទីនៅនៃពស់) ក្នុងសីតវ័ន (ព្រៃត្រជាក់) ទៀបក្រុងរាជគ្រឹះនោះ។ តថាគតនៅក្នុងតបោទារាម (អារាមជិតស្ទឹងឈ្មោះតបោទា) ជិតក្រុងរាជគ្រឹះនោះ។ តថាគតនៅក្នុងវេឡុវ័នកលន្ទកនិវាបស្ថានជិតក្រុងរាជគ្រឹះ។ តថាគត នៅក្នុងជីវកម្ពវ័នជិតក្រុងរាជគ្រឹះនោះ។ តថាគតនៅក្នុងមទ្ទកុច្ឆិមិគទាយវ័នជិតក្រុងរាជគ្រឹះនោះ។ ម្នាលអានន្ទ តថាគតនៅក្នុងទីអម្បាលនោះបានប្រាប់អ្នកថា ម្នាលអានន្ទ ក្រុងរាជគ្រឹះជាទីគួរត្រេកអរ ភ្នំគិជ្ឈកូដជាទីគួរត្រេកអរ គោតមនិគ្រោធជាទីគួរត្រេកអរ ជ្រោះសម្រាប់ទម្លាក់នូវចោរជាទីគួរត្រេកអរ សត្តបណ្ណគុហាខាងភ្នំវេភារៈជាទីគួរត្រេកអរ កាឡសិលាខាងភ្នំឥសិគិលិជាទីគួរត្រេកអរ សប្បសោណ្ឌិកបព្ភារៈក្នុងសីតវ័នជាទីគួរត្រេកអរ តបោទារាមជាទីគួរត្រេកអរ វេឡុវ័នកលន្ទកនិវាបស្ថានជាទីគួរត្រេកអរ ជីវកម្ពវ័នជាទីគួរត្រេកអរ មទ្ទកុច្ឆិមិគទាយវ័នជាទីគួរត្រេកអរ ម្នាលអានន្ទឥទ្ធិបាទទាំង ៤ បើបុគ្គលណា

មួយបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះបើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់១អាយុកប្ប ឬលើសជាង១អាយុកប្បក៏បាន ។ ម្នាលអានន្ទឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់១អាយុកប្ប ឬលើសជាង១អាយុកប្បក៏បាន ម្នាលអានន្ទ កាលបើតថាគតធ្វើនិមិត្តជាឱឡារិក ធ្វើឱភាសជាឱឡារិកយ៉ាងនេះហើយ អ្នកនៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនអារាធនាតថាគតថា សូមព្រះដ៏មានព្រះភាគទ្រង់ឋិតនៅអស់១អាយុកប្ប សូមព្រះសុគតឋិតនៅអស់១អាយុកប្ប

ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអារាធនាតថាគត តថាគតគប្បីឃាត់ពាក្យរបស់អ្នក ត្រឹមតែ២ ដងប៉ុណ្ណោះ គង់នឹងទទួលអារាធនាក្នុងវារៈជាគម្រប់ ៣ ដងមិនខាន ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

ម្នាលអានន្ទសម័យមួយតថាគតនៅក្នុងឧទេនចេតិយទៀបក្រុងវេសាលី។ ម្នាលអានន្ទសម័យមួយតថាគតនៅក្នុងគោតមកចេតិយជិតក្រុងវេសាលី។ តថាគតនៅក្នុងសត្តម្ពចេតិយជិតក្រុងវេសាលី ។ តថាគតនៅក្នុងពហុបុត្តចេតិយជិតក្រុងវេសាលី។ តថាគតនៅក្នុងសារន្ទទចេតិយជិតក្រុងវេសាលីនេះឯង។ ម្នាលអានន្ទក្នុងកាលឥឡូវនេះតថាគតនៅក្នុងបាវាលចេតិយ ក្នុងថ្ងៃនេះបានប្រាប់អ្នកថា

ម្នាលអានន្ទក្រុងវេសាលីជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះបើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់១អាយុកប្ប ឬលើសជាង១អាយុកប្បក៏បាន ។ ម្នាលអានន្ទឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់១អាយុកប្ប ឬលើសជាង១

អាយុកប្បក៏បាន ម្នាលអានន្ទ កាលបើតថាគតធ្វើនិមិត្តជាឱឡារិក ធ្វើឱភាសជាឱឡារិកយ៉ាងនេះហើយ ក៏អ្នកនៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បានមិន

អារាធនាតថាគតថា សូមព្រះដ៏មានព្រះភាគ ទ្រង់ឋិតនៅអស់១អាយុកប្ប សូមព្រះសុគត ទ្រង់ឋិតនៅអស់១អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើនដល់ទេវតា និងមនុស្សទាំងឡាយដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអារាធនាតថាគត តថាគតគប្បីឃាត់ពាក្យរបស់អ្នក ត្រឹមតែ ២ ដងប៉ុណ្ណោះ គង់នឹងទទួលអារាធនាក្នុងវារៈជាគម្រប់ ៣ ដងមិនខាន ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយនេះជាកំហុសរបស់អ្នកហើយ ម្នាលអានន្ទតថាគតប្រាប់អ្នកជាមុនហើយ យ៉ាងនេះថា សេចក្តីព្រាត់ប្រាស សេចក្តីវិនាស សេចក្តីប្រែប្រួលចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តទាំងអស់តែងមានជាធម្មតា ម្នាលអានន្ទ

ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ មិនព្រាត់ប្រាស ក្នុងខន្ធប្រវត្តិនេះអំពីទីណា ធម្មជាតិណា កើតឡើងហើយ មានហើយ សង្ខារតាក់តែងហើយ តែងមានសេចក្តីវិនាសទៅជាធម្មតា ធម្មជាតិនោះឯង បុគ្គលនឹងពោលឃាត់ថា កុំវិនាសដូច្នេះ (ដោយហេតុណា) ហេតុនោះមិនមានឡើយ ។ ម្នាលអានន្ទ មួយទៀតធម្មជាតិណាដែលតថាគតទាត់ចោលហើយ ខ្ជាក់ចោលហើយ ជម្រុះចោលហើយ លះបង់ចោលហើយ បន្សាត់ចោលហើយ អាយុសង្ខារតថាគតដាក់ចុះហើយ វាចាតថាគតពោលដោយពិតថា បរិនិព្វាននៃតថាគតមិនយូរឡើយកន្លង ៣ ខែ អំពីថ្ងៃនេះទៅតថាគតនឹងបរិនិព្វានហើយ តថាគតនឹងត្រឡប់មកកាន់ធម្មជាតិនោះវិញទៀត ព្រោះហេតុនៃជីវិតប៉ុណ្ណោះ (ដោយហេតុណា) ហេតុនោះមិនមានឡើយ ម្នាលអានន្ទមក យើងនឹងទៅកាន់កូដាគារសាលានាព្រៃមហាវ័ន ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគក៏ស្តេចចូលទៅកាន់កូដាគារសាលានាព្រៃមហាវ័នមួយអន្លើដោយព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅឲ្យពួកភិក្ខុទាំងប៉ុន្មានដែលអាស្រ័យនៅក្នុងក្រុងវេសាលីទាំងអស់នោះ មកជួបជុំក្នុងឧបដ្ឋានសាលា។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ឲ្យពួកភិក្ខុទាំងប៉ុន្មានដែលអាស្រ័យនៅក្នុងក្រុងវេសាលីទាំងអស់នោះមកជួបជុំក្នុងឧបដ្ឋានសាលា ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះមានព្រះភាគហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃប្រជុំគ្នាហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ ទ្រង់ជ្រាបនូវកាលគួរក្នុងកាលឥឡូវនេះ ។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណាធម៌ទាំងឡាយណា ដែលតថាគតសម្តែង ហើយដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើនធ្វើរឿយៗដោយប្រការដូច្នោះ។ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះគប្បីតាំងនៅអស់កាលអង្វែង គប្បី តម្កល់

នៅអស់កាលដ៏យូរ មួយទៀតសាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណាធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេពចម្រើន ធ្វើឲ្យរឿយៗ ដោយប្រការដូច្នោះធម៌ទាំងឡាយនោះតើដូចម្តេច?អ្វីខ្លះ? គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះគប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀតសាសនព្រហ្មចរិយៈនោះប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយដោយប្រការណា ធម៌ទាំងឡាយ

ណាដែលតថាគតសម្តែងហើយដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឲ្យរឿយៗដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះយ៉ាងនេះឯង។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា

**ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ។**

ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយមានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះៗ បរិនិព្វាន នឹងមានដល់តថាគត មិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគត នឹងបរិនិព្វានហើយ ៗ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីការ ដូច្នេះហើយ ក៏ទ្រង់មានព្រះពុទ្ធដីកា ដូច្នេះ តទៅទៀតថា

**ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា**
**អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា ។**

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះតែងមានសេចក្តីស្លាប់នៅពីខាងមុខ ។

**យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ**

**ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ**

**សព្វំ ភេទបរិយន្តំ ឯវំ មច្ចាន ជីវិតំ ។**

ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

ព្រះសាស្តា ទ្រង់មានព្រះពុទ្ធដីកាដូច្នេះ តទៅទៀតថា

**បរិបក្កោ វយោ មយ្ហំ បរិត្តំ មម ជីវិតំ បហាយ វោ**

**គមិស្សាមិ កតំ មេ សរណមត្តនោ ។**

វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគត មានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយ ហើយទៅឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ ។

**អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ**

**សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួនឲ្យរឿយៗចុះ ។

**យោ ឥមស្មិំ ធម្មវិនយេ អប្បមត្តោ វិហរិស្សតិ**
**បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតិ ។**

ភិក្ខុណាមិនប្រមាទហើយនៅក្នុងធម្មវិន័យនេះ ( ភិក្ខុនោះ ) នឹងលះបង់ជាតិសង្សារហើយធ្វើនូវព្រះនិព្វានជាទីបំផុតនៃកងទុក្ខបានមិនខាន ។

## សេចក្ដីពន្យល់របស់ព្រះអដ្ឋកថា

អដ្ឋកថាពោលថា ឈ្មោះថា មារ ក្នុងពាក្យថា មារោ បាបិមា នេះឈ្មោះថាមារ ព្រោះចងសត្វទុក ក្នុងសេចក្ដីវិនាស ធ្វើឲ្យស្លាប់។ ពិតមែន មារនោះ លោកហៅថាមារ ព្រោះប្រកបដោយបាបធម៌។ ក៏មារនេះជាប់តាមតាំងពីពោធិមណ្ឌលស្ថានក្នុងសប្ដាហ៍ទី៨ តាំងអំពីព្រះដ៏មានព្រះភាគទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណ ពោលថា ព្រះ

ដ៏មានព្រះភាគទ្រង់សម្រេចប្រយោជន៍របស់ព្រះអង្គដែលព្រះអង្គទ្រង់បំពេញព្រះបារមីមកដោយលំដាប់ហើយទ្រង់បានសម្រេចព្រះពោធិញ្ញាណហើយ ព្រះអង្គនឹងទ្រង់ត្រួតមើលលោកទៅ ហេតុដូចម្ដេចទើបទូលអង្វរថា ឥឡូវនេះសូមព្រះដ៏មានព្រះភាគ ទ្រង់បរិនិព្វាននៅក្នុងថ្ងៃនេះចុះព្រះអង្គ។ តែព្រះដ៏មានព្រះភាគទ្រង់ត្រាស់បដិសេដដល់មារនោះថា តថាគតនឹងមិនបរិនិព្វាន ដូច្នេះជាដើម។ មារសំដៅយកសេចក្ដីនោះ ទើបពោលថា ឝាសិតា ខោ បនេសា ឝន្តេ ជាដើម។

សួរថាទ្រង់ឧទានព្រោះហេតុអ្វី? ឆ្លើយថា ព្រោះបានឮថា ឈ្មោះថា អ្នកណាៗនឹងគប្បីនិយាយថា ព្រះដ៏មានព្រះភាគ ត្រូវមារជាប់តាមទៅខាងក្រោយៗអង្វររុកកួនថា មេត្តាបរិនិព្វានចុះ ព្រះអង្គៗ ទ្រង់ដាក់អាយុសង្ខារមិនមែនព្រោះខ្លាច ទើបទ្រង់ថ្លែងព្រះឧទានដែលថ្លែងដោយកម្លាំងបីតិ ដើម្បីសម្ដែងសេចក្ដីនេះថា ឈ្មោះថា ពាក្យ

ឧទានរមែងមិនមានដល់អ្នកខ្លាចថាសូមមារកុំមានឱកាសឡើយ។ព្រះឧទានវាចារបស់ព្រះដ៏មានព្រះភាគ

**តុលមតុលញ្ច សម្ភវំ ភវសង្ខារមវស្សជ្ជិ មុនិ អជ្ឈត្តរតោ សមាហិតោ អភិន្ទិ កវចមិវត្តសម្ភវន្តិ ។**

ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វាន ដែលមានគុណថ្លឹងមិនបានផង នូវភពផង ទ្រង់លះបង់នូវសង្ខារ ដែលនាំសត្វទៅកាន់ភព ទ្រង់ត្រេកអរនូវអារម្មណ៍ខាងក្នុង (ដោយអំណាចវិបស្សនា) មានព្រះហឫទ័យតាំងមាំហើយ (ដោយអំណាចសមថៈ) ទ្រង់បានទំលាយនូវបណ្តាញ គឺកិលេស ដែលកើតមាននៅក្នុងព្រះអង្គដូចជាក្រោះ។

អធិប្បាយគាថា ឈ្មោះថា តុល ព្រោះថ្លឹងកំណត់ដោយភាវៈដែលប្រចក្ស របស់សត្វមានឆ្កែស្រុកឆ្កែព្រៃជាដើមទាំងអស់។កម្មដែលថ្លឹងបាននោះដូចម្តេច? បានដល់កម្មផ្នែកកាមាវចរៈឈ្មោះថា អតុល ព្រោះថ្លឹងមិនបាន។ឬលោកិយកម្មយ៉ាងដទៃ ដែលប្រៀបនឹងកាមាវចរកម្មនោះ

មិនមាន។ កម្មដែលថ្លឹងមិនបាននោះយ៉ាងណា បានដល់កម្មផ្ទែក មហគ្គតៈ។ បទថា សម្ភវំ បានដល់កម្មដែលធ្វើជាដុំ អធិប្បាយថា ធ្វើជាកងដែលជាហេតុកើត។ បទថា ភវសង្ខារំ បានដល់កម្មដែលតាក់តែងភពថ្មី។ បទថា អវស្សជ្ជិ បានដល់ ធ្លាក់ចុះ។ បទថា មុនី បានដល់អ្នកប្រាជ្ញគឺព្រះពុទ្ធ។ បទថា អជ្ឈត្តរតោ គឺត្រេកអរខាងក្នុងពិតប្រាកដ។ បទថា សមាហិតោ គឺតាំងមាំហើយ ដោយឧបចារសមាធិ និងអប្បនាសមាធិ។ បទថា អភិន្ទិ កវចមិវ បានដល់ទម្លាយកិលេស ដូចកោះ។ បទថា អត្តសម្ភវំ បានដល់កិលេសដែលកើតហើយក្នុងខ្លួន។ លោកអធិប្បាយទុកថា ព្រះមុនីទ្រង់រួចផុតពីលោកិយកម្ម ពោលគឺតុលកម្ម និងអតុលកម្ម ដែលបានឈ្មោះថា សម្ភវៈ ព្រោះអត្ថថាមានវិបាក ថាភវសង្ខារ ព្រោះអត្ថថាតាក់តែងភព និងទ្រង់ត្រេកអរខាងក្នុងតាំងមាំហើយ ទម្លាយកិលេស ដែលកើតក្នុងខ្លួន ដូចអ្នកច្បាំងធំ ក្នុងសមរភូមិទម្លាយកោះ

ដូច្នោះ។ ន័យមួយទៀត តុលំ ថ្លឹងគឺពិចារណា។ ភវសង្ខារំ កម្មដែលទៅកាន់ភព។ បទថា **អវស្សជ្ជិ** មុនី សេចក្តីថាព្រះមុនីគឺព្រះពុទ្ធទ្រង់ពិចារណាដោយន័យជាអាទិ៍ថា បញ្ចក្ខន្ធមិនទៀងការរលត់បញ្ចក្ខន្ធគឺ និព្វានជារបស់ទៀង ទ្រង់ឃើញទោសក្នុងភព និងឃើញអានិសង្សក្នុងព្រះនិព្វានហើយ ទ្រង់បណ្តោយតាមអរិយមគ្គ ដែលធ្វើនូវការអស់កម្ម ដែលលោកពោលទុកយ៉ាងនេះថាកម្មគ្រឿងតាក់តែងភពដែលជាមូលនៃខន្ធទាំងឡាយនោះប្រព្រឹត្តទៅដើម្បីអស់កម្ម ដូច្នេះ។ ព្រះអង្គទ្រង់ត្រេកអរខាងក្នុង តាំងមាំហើយ ទ្រង់ទម្លាយកិលេសដែលកើតក្នុងខ្លួន ដូចជាក្រោះបានយ៉ាងណា។ សេចក្តីពិតព្រះមុនីនោះទ្រង់ត្រេកអរខាងក្នុង ដោយអំណាចវិបស្សនាទ្រង់តាំងមាំដោយអំណាចសមថៈរួមសេចក្តីថា ព្រះអង្គទ្រង់ទម្លាយសំណាញ់គឺកិលេសទាំងអស់ ដែលជាគ្រឿងរួបរឹតអត្តភាពដូចក្រោះ ដែលបានឈ្មោះថា **អត្តសម្ភវៈ**

ព្រោះកើតក្នុងខ្លួន ដោយកម្លាំងសមថៈ និងវិបស្សនាតាំងពីខាងដើម និងលះកម្ម ដោយការលះកិលេសយ៉ាងនេះថា កម្មដែលធ្វើដោយមិនមានកិលេសឈ្មោះថានៅសល់ព្រោះមិនមានបដិសន្ធិ។ គប្បីជ្រាបថាឈ្មោះថាសេចក្តីខ្លាចរបស់អ្នកលះកិលេស បានហើយមិនមានព្រោះដូច្នោះ ព្រះមុនីទ្រង់មិនខ្លាច ហើយទើបទ្រង់ដាក់អាយុសង្ខារ ព្រោះហេតុនោះ ទើបទ្រង់ថ្លែងឧទានដើម្បីឲ្យដឹងថា ទ្រង់មិនខ្លាច។

## កំណាព្យ ព្រះអង្គទ្រង់ដាក់អាយុសង្ខារ

អង្គព្រះទ្រង់ញាណមានតេជះ សម្តែងប្រាប់ព្រះអានន្ទថា
រទេះដែលចាស់បរទៅណា ទៅបានដោយសារអបឫស្សី។
តថាគតចាស់គ្រាំគ្រាហើយ ម្នាលអានន្ទអើយមានមាំអី
ដូចរទេះចាស់អបឫស្សី វស្សាឆ្នាំថ្មីប៉ែតសិបហើយ។
ក្រោយព្រះអានន្ទទ្រង់ចេញផុត ពីព្រះសម្ពុទ្ធមិនឃ្លូវឡើយ
ក្រោយភត្តាហារថ្ងៃត្រង់ហើយ មារមិនកន្តើយគាល់សាស្តា។

ឆ្នាំម្សាញ់ខែមាឃថ្ងៃអាទិត្យ ពេញបូណ៌មីពិតថ្ងៃនោះណា
ព្រះអង្គទ្រង់ដាក់អាយុសង្ខារ ចំពោះមុខមារគ្រានោះឯង។
នៅនាបាវាលចេតិយ ក្បែរវេសាលីក្រៅកំផែង
កក្រើកធរណីរគ្រប់កន្លែង ផ្គរលាន់ខ្ទាត់ខ្ទែងខ្ទរអាកាស។
ក្រោយមកភិក្ខុជួបជុំគ្នា អង្គព្រះភគវាទ្រង់បានត្រាស់
សម្តែងគាថាអស្ចារ្យណាស់ រំលឹកយ៉ាងច្បាស់ត្រាស់ឱវាទ។
ទ្រង់បានត្រាស់ថាសង្ខារទាំងឡាយ តែងតែអន្តរាយវិនាសខូចខាត
ចូរអ្នកទាំងឡាយកុំបីប្រមាទ ប្រឹងប្រែងសង្វាតឲសម្រេចការ។
ភាជន៍ដែលស្មូនឆ្នាំងដំដុតដោយដី តូចក្តីធំក្តីឆៅឆ្អិនយ៉ាងណា
ចុងក្រោយរមែងតែងមានកិរិយា បែកធ្លាយធម្មតានេះជាការពិត។
យ៉ាងណាជីវិតសព្វសត្វនិករ ក្មេងចាស់មានក្រពាលឬបណ្ឌិត
ចុងក្រោយរមែងតែងតែស្លាប់ពិត បាត់បង់ជីវិតក៏យ៉ាងនោះដែរ។
ជីវិតតថាគតមានប្រមាណតិច គោរពពាក្យពេចន៍ឥតគេចកែប្រែ
ពីថ្ងៃនេះទៅនៅត្រឹមបីខែ តថាគតត្រូវតែបរិនិព្វាន។
បីខែកន្លងយ៉ាងរហ័ស សែនសោកស្តាយណាស់ព្រះទ្រង់ញាណ
វេលាជិតភ្លឺទ្រង់ចូលឈាន ហើយចូលនិព្វានកណ្តាលព្រៃ។
ក្នុងខែពិសាខថ្ងៃអង្គារ ឆ្នាំម្សាញ់វេលាចុងរាត្រី

ថ្ងៃដប់ប្រាំកើតពេញបូណ៌មី បរិស័ទប្រុសស្រីជុំត្រៀបត្រា។
ទីទ្រង់និព្វាននោះតាំងនៅ ក្បែរផ្លូវទៅក្រុងកុសិនារា
រាំងភ្នំមួយគួរសាលព្រឹក្សា មានផ្ទៃសិលានៅចន្លោះ។
កុំថាឡើយមនុស្សសោយសោកា សូម្បីទេវតាឋានទាំងអស់
យំសោកបោកប្រាណស្តាយស្រណោះ លាន់កក្រើកអស់ភពផែនដី។
ទីទ្រង់និព្វាននោះតទ្បូវ មានស្តូបតាំងនៅល្អប្រិមប្រិយ
សម្គាល់ទីដែលព្រះជិនស្រី និព្វានលើដីកុសិនារា។
ក្នុងស្តូបមានព្រះបដិមាថ្ម កសាងយ៉ាងល្អគួរជ្រះថ្លា
តំណាងព្រះសពព្រះសាស្តា ស្តូកស្តឹងកាយាសែនអាសូរ។
អ្នកទៅដល់ពិតចិត្តដិតជាប់ ឃើញដូចព្រះសពនៅជ្រងោ
មានស្បង់ចីវរថ្វាយផ្លាស់ប្តូរ ទឹកនេត្រាហូរនឹកព្រះអង្គ។
នឹកហាក់ដូចជានៅថ្មីៗ នឹកព្រះជិនស្រីប្រោសស្រោចស្រង់
នឹកដល់ព្រះធ៌មល្អផូរផង់ នឹកទាំងព្រះសង្ឃអង្គសាវ័ក។
ចាប់តាំងអំពីថ្ងៃនេះទៅ សូមដើរតាមផ្លូវព្រះអរិយៈ
ក្រោមម្លប់ព្រះធ៌មដ៏ត្រជាក់ ផុតពីអន្ទាក់នៃពួកមារ។
សូមឲលោកអ្នកបានសូត្រស្តាប់ ប្រវត្តិសារស័ព្ទព្រះភគវា
បានសុខចម្រើនគ្រប់ៗគ្នា កុំបីឃ្លាតឃ្លាគ្រាណាឡើយ។

ឯវំ វុត្តេ ភគវា មារំ បាបិមន្តំ ឯតទវោច អប្បោស្សុក្កោ ត្វំ បាបិម ហោហិ ន ចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ, កាលបើក្រុងមារក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏បានត្រាស់ភាសិតនេះទៅនឹងក្រុងមារមានចិត្តបាបថា ' ម្នាលមារមានចិត្តបាប អ្នកចូរមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែ អំពីថ្ងៃនេះទៅតថាគតនឹងបរិនិព្វានហើយ។

## វិធីប្រកាសមាឃបូជា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ។

**សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វទុក្ខស្ស បហានាយ ធម្មំ ទេសេតិ តំ សម្មាសម្ពុទ្ធំ អាទរេន នមស្សាមិ។**

ព្រះភគវន្តមុនីអង្គឯណា ទ្រង់ត្រាស់សំដែងនូវធម៌ ដើម្បីកំចាត់បង់នូវសេចក្ដីទុក្ខទាំងពួង, ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព។ (ក្រាបថ្វាយបង្គំម្ដង)

**និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខស្សបហានាយ ស្វាក្ខាតោ តេន ភគវា តំ ធម្មំ អាទរេន នមស្សាម។**

ព្រះធម៌ណាដែលព្រះភគវន្តមុនីអង្គនោះទ្រង់ត្រាស់សំដែងហើយដោយប្រពៃ ដើម្បីកំចាត់បង់នូវសេចក្ដីទុក្ខ ទាំងពួង, ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះធម៌នោះ ដោយគោរព។ (ក្រាបថ្វាយបង្គំម្ដង)

សុប្បដិបន្នោ វតស្ស ភគវតោ សោ សាវកសង្ឃោ យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ អាទរេន នមស្សាម។

ព្រះអរិយសង្ឃណា លោកប្រតិបត្តដើម្បីកម្ចាត់បង់នូវសេចក្ដីទុក្ខទាំងពួង,ព្រះអរិយសង្ឃនោះជាសង្ឃសាវ័កនៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិ ដោយប្រពៃពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព។ (ក្រាបថ្វាយបង្គំម្ដង)

ថ្ងៃនេះ ជាតិថីពេញបូណ៌មី នៃខែមាឃ មានព្រះច័ន្ទពេញវង់ត្រូវនឹងថ្ងៃនៃសាវ័កសន្និបាត របស់ព្រះសាក្យមុនីអរហន្តសម្មាសម្ពុទ្ធ ជាបរមគ្រូនៃយើង, សាវ័កសន្និបាតនោះ ប្រកបដោយអង្គ៤គឺ៖

ទី១ ថ្ងៃពេញបូណ៌មីខែមាឃ ព្រះច័ន្ទចរចូលក្នុងមាឃនក្ខត្តឫក្ស។

ទី២ ព្រះភិក្ខុសង្ឃ មានចំនួន ១២៥០ អង្គ ឥតមានអ្នកណានិមន្ត ឬណាត់ពេលវេលាគ្នាសោះឡើយ ក៏ស្រាប់តែមកប្រជុំគ្នា ក្នុងសំណាក់នៃព្រះបរមសាស្ដា នាវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ក្រុងរាជគ្រឹះ មគធរដ្ឋ នៅវេលាថ្ងៃល្ងាច។

ទី៣ ព្រះភិក្ខុសង្ឃទាំង ១២៥០ អង្គនោះ សុទ្ធតែជាឯហិភិក្ខុ ដូចគ្នាទាំងអស់។

ទី៤ ព្រះភិក្ខុសង្ឃទាំង ១២៥០ អង្គនោះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់។ ព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់សំដែងនូវឱវាទបាដិមោក្ខក្នុងទីប្រជុំនៃព្រះភិក្ខុសង្ឃនោះ។

ការប្រជុំសាវ័កបែបនេះ ហៅថា "ចតុរង្គសន្និបាត" គឺការប្រជុំប្រកបដោយអង្គ៤ ក្នុងពុទ្ធកាលនៃព្រះសក្យមុនីបរមគ្រូរបស់យើងមានតែម្ដងប៉ុណ្ណោះ។

មួយទៀត កាលដែលព្រះបរមសាស្ដានៃយើងទ្រង់មានព្រះជន្ម បើគិតតាមឈ្មោះខែ នៅខ្វះ ៤ ខែ, បើគិត

តាមចំនួនថ្ងៃ នៅខ្វះតែ ៨៨ ថ្ងៃទៀត នឹងគ្រប់ ៨០ ឆ្នាំគត់ ព្រះអង្គទ្រង់កំណត់នូវព្រះជន្មាយុសង្ខារថា "ម្នាលភិក្ខុទាំងឡាយ គិតពីថ្ងៃនេះទៅ នៅខ្វះតែ ៣ ខែទៀតទេ តថាគតនឹងរលត់ខន្ធចូលកាន់និព្វាន"។ ការកំណត់ព្រះជន្មាយុនេះ គឺនៅថ្ងៃ ១៥ កើត ខែមាឃនេះឯង។ តិថីនេះជាឧបលក្ខិតសម័យដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធមាមកជន ទាំងបព្វជិតទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការៈបូជា ចំពោះព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ជាបរមពុទ្ធោវាទនិងព្រះអរិយសង្ឃជាសាវ័ករបស់ព្រះអង្គ។

ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នា បានរៀបចំគ្រឿងសក្ការបូជា មានទៀនធូបនិងផ្កាជាដើម ក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គ (បើមានព្រះបរមសារីរិកធាតុ ត្រូវបញ្ចូលពាក្យថា "និងព្រះបរមសារីរិកធាតុ"ផង) គង់ជាប្រធាន ហាក់ដូចជាព្រះបរមសាស្តាអង្គ

នោះ ទ្រង់ស្ដេចមកគង់ក្នុងទីចំពោះមុខនៃយើងទាំងអស់គ្នា យើងខ្ញុំសូមថ្វាយនូវគ្រឿងសក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃនៃរតនត្រៃទាំងបី ដោយសេចក្ដីគោរព។

បពិត្រព្រះសក្យមុនីបរមគ្រូព្រះអង្គជាបូជារហបុគ្គលរបស់ទេវតា និងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយត្រឹមស្មើនឹងព្រះអង្គឡើយទោះបីព្រះអង្គ ចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយ អស់កាលយូរអង្វែងទៅហើយក៏ពិតមែន, ប៉ុន្តែទ្រង់បានប្រតិស្ឋានព្រះវិសុទ្ធោវាទ គឺព្រះធម៌ វិន័យ ដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះពុទ្ធអង្គ ទ្រង់ព្រះគុណរបស់ព្រះអង្គក៏នៅមានប្រាកដ ទាំងព្រះសារីរិកធាតុនិងព្រះពុទ្ធរូប ស្នងព្រះអង្គក៏នៅមានប្រាកដដែរ សូមព្រះដ៏មានបុណ្យជាបរមសាស្ដា ទ្រង់ព្រះមេត្តាទទួលនូវគ្រឿងសក្ការបូជា របស់យើងខ្ញុំព្រះអង្គដែលបានរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្ស ឲ្យ

យើងខ្ញុំព្រះអង្គ បានប្រកបដោយឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្តីចម្រើនដ៏ធំទូលាយ អស់កាលជាអង្វែងទៅហោង។

## ធម៌ត្រៀងសក្ការៈបូជា ទាំងបាលី និងសម្រាយ

អជ្ជាយំ ភន្តេ មាឃបុណ្ណមី សម្បត្តោ មាឃនក្ខត្តេន យុត្តោ បុណ្ណចន្ទោ ហោតិ តទា ហិ អរហន្ត សម្មាសម្ពុទ្ធោ វេឡុវនេ កលន្ទកនិវាបេ មាឃបុណ្ណមិយំ វឌ្ឍមានកច្ឆាយាយ ចតុរង្គិកេ សាវកសន្និបាតេ ឱវាទបាតិមោក្ខំ ឧទ្ទិសិត្វា វិសុទ្ធុបោសថំ អកាសិ សព្វេសំ ខីណាសវានំយេវ អឌ្ឍតេឡសាន ភិក្ខុសតានំ។

អថ ច បន អម្ហាកំ លោកនាយកោ បាវាលចេតិយេ សតោ សម្បជានោ អសីតិយា វស្សកាលេ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សាមីតិ អាយុសង្ខារំ ឱស្សជ្ជិ ឱស្សជ្ជិត្វា ច បន ភូមិបាលោ អហោសិ។

តេន ហិ មយន្ទានិ ឥមំ មាឃបុណ្ណមឹ នក្ខត្តសមយំ យថាត ក្កាលសទិសំ សម្បត្តោ តស្ស តំ តំ អនុស្សមានោ ឥធ សមា គតា រតនត្តយស្ស ឥមេហិ ទីបធូបបុប្ផាទិសក្ការេហិ អភិបូ ជេម សាធុ នោ ភន្តេ ភគវា សាវកសង្ឃោ សុចិរបរិនិព្វុតោ បិ ឥមេ សក្ការេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ប្រែថា: បពិត្រ លោកទាំងឡាយដ៏ចម្រើន ថ្ងៃនេះជាថ្ងៃ មាឃបុណ្ណមី ដល់ព្រមហើយប្រកបដោយ មាឃនក្ខត្តឫក្ស មានព្រះច័ន្ទពេញវង់ប្រាកដ, សេចក្ដីពិតថា ព្រះអរហន្ត សម្មាសម្ពុទ្ធ ទ្រង់ប្រថាប់នៅក្នុងវេឡុវ័ន កលន្ទកនិវា បស្ថាន សម្ដែងនូវឱវាទបា្បតិមោក្ខ ធ្វើវិសុទ្ធិឧបោសថ ចំពោះភិក្ខុដប់ពីររយ ដោយកន្លះគឺ (១២៥០) អង្គ សុទ្ធតែ ជាព្រះខីណាស្រពទាំងអស់ក្នុងទីប្រជុំសាវ័ក ប្រកបដោយ អង្គ ៤ វេលារសៀលថ្ងៃពេញបូណ៌មី ខែមាឃ ។

មួយវិញទៀត សម្តេចព្រះលោកនាយក អម្ចាស់នៃយើង ទ្រង់ប្រថាប់នៅក្នុងបាវាចេតិយ ទ្រង់មានសតិសម្បជញ្ញៈ ដាក់ចុះនូវព្រះជន្មាយុសង្ខារ ថាកន្លងទៅបីខែទៀត រាប់តាំងអំពីខែនេះ តថាគតនឹងបរិនិព្វាន គម្រប់ព្រះជន្មាយុ ៨០ឆ្នាំគត់ លុះទ្រង់ដាក់ព្រះជន្មាយុសង្ខារហើយ ក៏កើតញាប់ញ័រផែនដី ។

ព្រោះហេតុនោះឥឡូវនេះ យើងខ្ញុំទាំងឡាយ(បើ)ដល់ ថ្ងៃមាឃបុណ្ណមី ជានក្ខត្តសម័យប្រហែល ដូចមាឃនក្ខត្តសម័យ កាលនោះក៏រលឹកដល់ នូវកាលទាំងពីរនោះ របស់ព្រះដ៏មានព្រះភាគ ទើបមកជុំគ្នាក្នុងស្ថាននេះ ធ្វើបូជាចំពោះព្រះរតនត្រ័យ ដោយគ្រឿងសក្ការៈបូជាទាំងឡាយ មានទៀនធូប កម្រងផ្កាជាដើមនេះ , បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ព្រម ទាំងព្រះសង្ឃសាវ័ក សូម្បីបរិនិព្វានហើយជាយូរអង្វែង សូមទទួលនូវគ្រឿងសក្ការៈទាំងឡាយនេះ ដើម្បីជា ប្រយោជន៍

និងដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង៕

លុះចប់វិធីប្រកាសមាឃបូជាហើយ សូមនិមន្តព្រះសង្ឃទាំងអស់នមស្ការព្រះរតនត្រ័យតាមវិធីប្រណាម(នមស្ការ) និងធម៌សម្រាប់នមស្ការផ្សេងៗទៀតតាម ដែល អាចសូត្របានគ្រប់ព្រះអង្គ។ តទៅសូមឲ្យភិក្ខុឬសាមណេរ មានសំឡេងពីរោះដែលបានហាត់ហើយសូធ្យ២អង្គៗនូវ នមស្ការ គាថាហើយនិមន្តធម្មកថិកសំដែងធម៌ទេសនា ។ លុះចប់ធម៌ទេសនាហើយពុទ្ធបរិស័ទណា ចង់សូធ្យបទផ្សេងៗ ដែលស្របនឹងបុណ្យនេះក៏សូមសូធ្យ ទាល់តែភ្លឺទៅចុះ ៕ (ចប់សាសនកិច្ចនៃមាឃបូជា ដោយសង្ខេប)

## នមោ៨បទ

**នមោអរ ហតោសម្មា សម្ពុទ្ធស្ស មហេសិនោ**

ខ្ញុំសូមបង្គំ ឆ្ពោះព្រះអរហន្ត សម្ពុទ្ធភគវន្ត កាលស្វែងរកធម៌ ។

គឺពោធិញ្ញាណ ប្រសើរបវរ បានត្រាស់ដឹងធម៌ ដោយអរិយមគ្គ។

**នមោឧត្ត មធម្មស្ស ស្វាក្ខា តស្សេ វតេនិធ**

សូមថ្វាយបង្គំ ព្រះធម៌ឧត្តម ដែលព្រះបរម សម្តុទ្ធសម្តែង ។ ដោយប្រពៃពិត ប្រាកដជាក់ស្តែង ព្រះធម៌នោះឯង ទុកក្នុង សាសនា ។

**នមោមហា សង្ឃស្សា បិ វិសុទ្ធសី លទិដ្ឋិនោ**

សូមថ្វាយបង្គំ ព្រះសង្ឃប្រសើរ ដែលលោកបានធ្វើ ទិដ្ឋិនិងសីល ឲ្យបានបរិសុទ្ធ ផុតចាកមន្ទិល គឺទិដ្ឋិសីល លោកស្អាតអស់ ហើយ ។

**នមោឱមា ត្យារិទ្ធស្ស រតនត្តយស្សសាធុកំ**

សូមថ្វាយបង្គំ ប្រជុំត្រ័យរ័ត្ន ប្រារព្ធដោយបទ មានបីប្រការ ។ ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃឈ្នះមារ ប្រសើរអស្ចារ្យ ថ្លឹងថ្លែងពុំបាន

**នមោឱម កាតីតស្ស តស្សវត្ថុត្តយស្សាបិ**

សូមថ្វាយបង្គំ ភ្នំវត្ថុបី ពិសេសពិសី ប្រសើរច្រើនថ្កាន ។ ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃសព្វឋាន តេជះកល្យាណ ដោយ គុណាគួរគាប់ ។

**នមោការ ឬ្បតាវេន វិគច្ឆន្តុ ឧបទ្ទវា**

សូមថ្វាយបង្គំ ត្រ័យរ័ត្នសោភា ឧបទ្រពនានា ចូរវិនាសបាត់ ។
ដោយអានុភាព បុណ្យជួយកំចាត់ ធ្វើក្តីវិបត្តិឲ្យស្ងាត់សូន្យទៅ។

**នមោការា នុភាវេន សុវត្ថិហោ តុសព្វទា**

សូមថ្វាយបង្គំ ត្រ័យរ័ត្នទាំងបី សូមសុខសួស្តី កើតសព្វវេលា ។
ដោយអានុភាព ធ្វើការវន្ទា គោរពបូជាគុណព្រះត្រ័យរ័ត្ន។

**នមោការ ស្សតេជេន វិធិម្ហិហោ មិតេជវា**

សូមថ្វាយបង្គំ ត្រ័យរ័ត្នសោភា តេជះចេស្តា ចូរមានដល់ខ្ញុំ។
ក្នុងពិធីធ្វើ កិច្ចថ្វាយបង្គំ តេជះបុណ្យធំ សូមកើតឡើងហោង ។

## ពាក្យសរសើរគុណព្រះរតនត្រ័យ!!

បពិត្រព្រះពុទ្ធទាំងឡាយមានព្យាយាមធំ ព្រះអង្គកាលនៅក្នុងសំសារវដ្ត ប្រកបដោយភ័យទាំងពួង ទ្រង់មានព្រះទ័យនឿយណាយអំពីវដ្តទុក្ខទាំងពួង តែទ្រង់មិនទាន់បរិនិព្វាន ព្រោះមានសេចក្តីអាណិតក្រៃពេក ដល់ពួកសត្វទាំងអស់ ដែលមានក្នុងចក្រវាឡជាអនន្តទាំងអស់ ព្រោះ

ហេតុនោះ ព្រះមហាមុនីទាំងឡាយ ឈ្មោះថាប្រកបដោយករុណា យើងខ្ញុំទាំងឡាយសូមនមស្ការនូវមហាករុណាគុណនៃព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គទាំងអស់នោះ ដោយសេចក្តីគោរពកោតក្រែងសព្វកាលគ្រប់ទិសទី។

ព្រះសព្វញ្ញូពុទ្ធទាំងអស់ សុទ្ធតែមានការព្យាយាមធំព្រះអង្គបំពេញហើយនូវបារមីធម៌ទាំង១០គឺទ្រង់ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ មានប្រការផ្សេងៗ អស់៤អសង្ខេយ្យមួយសែនកប្បខ្លះ អស់៨អសង្ខេយ្យមួយសែនកប្បខ្លះ អស់១៦អសង្ខេយ្យមួយសែនកប្បខ្លះ ហើយទ្រង់កន្លងផុតនូវផ្លូវឆ្ងាយគឺជាតិ ទ្រង់បន្សាត់បង់នូវមន្ទិលគឺកិលេសទាំងអស់ មិនឱ្យមានសេសសល់ ហើយទ្រង់សម្រេចនូវពោធិញាណទាំងអស់ផង នូវពុទ្ធញាណទាំង ១៤ ផង ទ្រង់ជ្រាបច្បាស់នូវញេយ្យធម៌ទាំងពួងរកទីបំផុតគ្មានផង ព្រះអង្គបរិបូរណ៍ដោយអាការៈប្រសើរគ្រប់យ៉ាងបរិបូរណ៍ដោយគុណទាំងពួង យើងខ្ញុំទាំងឡាយ សូម

នមស្ការនូវគុណដ៏ប្រសើរសព្វគ្រប់នៃព្រះពុទ្ធទាំងអស់ នោះដោយសេចក្តីគោរពកោតក្រែងសព្វកាលគ្រប់ទិសទី

ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់មិនមានបុគ្គលស្មើដោយព្រះរូបផង ដោយសំឡេង ក្លិន រស សម្ផស្ស ឱជាធម្មារម្មណ៍ទាំងឡាយផង ទ្រង់ជាអចិន្តេយ្យបុគ្គលមិនមានបុគ្គលស្មើដោយយសផង ដោយតេជះផង ដោយកម្លាំងកាយផង ដោយឫទ្ធានុភាពផង ទ្រង់មិនមានបុគ្គលស្មើដោយសីល សមាធិ បញ្ញាផង ព្រះអង្គស្មើដោយព្រះសព្វញ្ញុពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើចំពោះវិមុត្តិនិងការញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ។ ព្រះអង្គ បរិបូរណ៍ដោយសេចក្តីសុខគ្រប់យ៉ាង ទ្រង់មានយសនិងតេជះជាអនន្ត គេគ្រប់សង្កត់មិនបានដូចជាអាកាស ទ្រង់ឈ្លាសវៃក្នុងធម៌សព្វគ្រប់មិនមានសេសសល់ តែងទូន្មានដឹកនាំសត្វទាំងឡាយ ឱ្យទៅកាន់សុគតិនិងព្រះនិព្វានដ៏វិសេស ព្រះអង្គមានព្រះកិត្តិគុណល្បីផ្សាយទៅសព្វទិសទី ទ្រង់ជា

ទីស្រឡាញ់ពេញចិត្ត ជាទីគោរពរាប់អានបូជានៃមនុស្ស ទេវតាសព្វសត្វទាំងឡាយ ទ្រង់កន្លងផុតនូវគន្លងនៃពាក្យទាំងពួង ទ្រង់ដល់នូវត្រើយនៃញេយ្យធម៌ទាំងពួង យើងខ្ញុំទាំងឡាយ សូមនស្ការនូវគុណដ៏ប្រសើរសព្វគ្រប់ នៃព្រះពុទ្ធគ្រប់ព្រះអង្គទាំងអស់នោះ ដោយសេចក្តីគោរពកោតក្រែងសព្វកាលគ្រប់ទិសទី។

ព្រះមហាមុនីទាំងឡាយ មានការអត់ធន់នឹងលោកធម៌ប្រៀបដោយផែនដី មានសីលប្រៀបដោយសមុទ្រសាគរ មានសមាធិប្រៀបដោយភ្នំសិនេរុ មានព្រះបញ្ញាញាណប្រៀបដោយលំហអាកាស ទ្រង់ជ្រាបច្បាស់នូវធម៌ទាំងអស់មិនមានសេសសល់ ព្រះអង្គប្រកបដោយសេចក្តីអនុគ្រោះក្រៃពេក តែងប្រកាសសម្តែងនូវធម៌ដ៏ប្រសើរដើម្បីជាប្រយោជន៍ដល់សព្វសត្វទាំងឡាយសព្វកាល យើងខ្ញុំទាំងឡាយសូមនមស្ការនូវគុណដ៏ប្រសើរសព្វគ្រប់

របស់ព្រះពុទ្ធគ្រប់ព្រះអង្គទាំងអស់នោះ ដោយសេចក្តីគោរពកោតក្រែងសព្វកាលគ្រប់ទិសទី។

គេអាចវាស់អាកាសដោយខ្សែ ឬដោយម្រាមដៃបានឯព្រះសព្វញ្ញុតញ្ញាណរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ គេមិនអាចវាស់បានឡើយចិត្តរបស់សត្វទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងមនុស្សលោក ព្រមទាំងទេវលោក បពិត្រព្រះសព្វញ្ញូមានចក្ខុ(ទាំង ៥ មានសមន្តចក្ខុជាដើម) ពួកសត្វដែលមានចិត្តក្នុងចក្រវាឡជាអនន្តទាំងអស់នោះរមែងតាំងនៅខាងក្នុងនៃសំណាញ់ញាណរបស់ព្រះអង្គយើងខ្ញុំទាំងឡាយសូមនមស្ការនូវព្រះសព្វញ្ញុតញាណនៃព្រះពុទ្ធគ្រប់ព្រះអង្គទាំងអស់នោះ ដោយសេចក្តីគោរពកោតក្រែងសព្វកាលគ្រប់ទិសទី។

ព្រះសយម្ភូជាទីពឹងនៃសត្វលោកព្រះអង្គប្រកប ដោយបញ្ញាហើយញុំាងមនុស្ស ព្រមទាំងទេវតាជាច្រើនរាប់មិនអស់ឱ្យឆ្លងចាកវដ្តសំសារដោយញាណដ៏ប្រសើររបស់ព្រះ

អង្គ ពួកសត្វទាំងអស់នោះ ព្រោះអាស្រ័យការជួបប្រទះនឹងព្រះអង្គទើបធ្វើនូវទីបំផុតនៃទុក្ខគឺព្រះនិព្វានបាន យើងខ្ញុំសូមនមស្ការនូវញាណដ៏ប្រសើរ នៃព្រះពុទ្ធគ្រប់ព្រះអង្គទាំងអស់នោះ ដោយសេចក្ដីគោរពកោតក្រែងសព្វកាលគ្រប់ទិសទី។

អសង្ខតធម៌ អចិន្តិយធម៌ មគ្គមានអង្គ ៨ ដ៏ប្រសើរ វិរាគធម៌ទាំងអស់ ព្រះបរិយត្តិធម៌ទាំងអស់ លោកុត្តរធម៌ទាំង ៩ ដ៏ប្រសើរវិសេស ព្រះធម៌ទាំងប្រាំបីម៉ឺនបួនពាន់ព្រះធម្មខន្ធដ៏ប្រសើរខ្ពង់ខ្ពស់និងព្រះធម៌ទាំងអស់ឯណា ដែលព្រះសព្វញ្ញុពុទ្ធគ្រប់ព្រះអង្គ ទ្រង់ពិចារណាហើយក្នុងទីនោះៗ ទ្រង់ត្រាស់សម្ដែងប្រកាសហើយ ក្នុងទីនោះៗ មានក្នុងឋានតាវតិង្សជាដើម ព្រមទាំងព្រះធម៌ទាំងអស់ឯណា ដែលមានក្នុងសន្ដានចិត្ត នៃព្រះសព្វញ្ញុពុទ្ធមានព្យាយាមធំគ្រប់ព្រះអង្គ ដែលជាបញ្ញាធិកក្ដី ដែលជាសទ្ធាធិកក្ដី ដែលជាវិរិយាធិកក្ដី ព្រះធម៌ទាំងអស់ឯណា ដែលមាន

ក្នុងសន្តានចិត្តនៃព្រះបច្ចេកពុទ្ធទាំងឡាយក្តី ដែលមានក្នុងសន្តានចិត្តនៃព្រះអរហន្តទាំងឡាយក្តី ដែលមានក្នុងសន្តានចិត្តនៃព្រះសង្ឃសាវ័កទាំងឡាយក្តី ដែលមានក្នុងសន្តានចិត្ត នៃពុទ្ធសាវ័កទាំងឡាយក្តី ដែលមានក្នុងសន្តានចិត្ត នៃឧបាសកឧបាសិកាទាំងឡាយក្តី ដែលមានក្នុង សន្តានចិត្តនៃបរិស័ទទាំង ៨ ពួកក្តី ដែលមានក្នុងសន្តានចិត្ត នៃព្រះពោធិសត្វទាំងឡាយជាដើមក្តី ជាធម៌ដ៏ប្រសើរកាត់ថ្លៃមិនបាន មិនមានអ្វីស្មើ ជាធម៌អាចដើម្បីញុំាងវដ្តទុក្ខទាំងពួងឱ្យអស់ទៅ ជាធម៌ប្រព្រឹត្តទៅដើម្បីប្រាសចាករាគាទិកិលេស ដើម្បីញុំាញីនូវសេចក្តីស្រវឹងក្នុងកាមទាំងឡាយដើម្បីកម្ចាត់បង់ នូវសេចក្តីអាល័យក្នុងកាម ដើម្បីផ្តាច់បង់នូវវដ្ត ដើម្បីអស់ទៅនៃតណ្ហា ដើម្បីប្រាសចាកតម្រេកអំពីវដ្តៈ ដើម្បីត្រាស់ដឹងចំពោះវដ្តៈ ដើម្បីស្ងប់រំងាប់នូវវដ្តៈ ដើម្បីរំលត់នូវវដ្តទុក្ខ ដើម្បីព្រះនិព្វាន យើងខ្ញុំសូមនមស្ការនូវធម៌ដ៏ប្រសើរ សព្វគ្រប់ទាំងអស់

នោះ ដោយសេចក្ដីគោរពកោតក្រែងសព្វកាលគ្រប់ទិសទី។

គុណដ៏ប្រសើរសព្វគ្រប់នៃព្រះបច្ចេកពុទ្ធទាំងឡាយគ្រប់ព្រះអង្គឯណា លោកជាអ្នកមានបញ្ញាមុតស្រួចលឿនរហ័ស ត្រាស់ដឹងនូវសច្ចធម៌តែមួយព្រះអង្គឯង យើងខ្ញុំព្រះករុណា សូមនមស្ការនូវគុណដ៏ ប្រសើរសព្វគ្រប់ នៃព្រះបច្ចេកពុទ្ធគ្រប់ព្រះអង្គទាំងអស់នោះ ដោយសេចក្ដីគោរពកោតក្រែងសព្វកាលគ្រប់ទិសទី។

ការមិនមានរាគាទិក្កិលេស ការបរិបូរណ៍ដោយសីល សមាធិ បញ្ញា នៃព្រះសង្ឃទាំងឡាយឯណា ជាសាវ័ករបស់ព្រះសុគត លោកជាអ្នកសង្រួមប្រតិបត្តិត្រឹមត្រូវតាមធម៌វិន័យទាំងប្រាំបីម៉ឺនបួនពាន់ព្រះធម្មខន្ធ ដែលព្រះសព្វញ្ញូពុទ្ធទ្រង់ត្រាស់សម្ដែងហើយដោយប្រពៃ យើងខ្ញុំទាំងឡាយសូមនមស្ការនូវគុណដ៏ប្រសើរសព្វគ្រប់ នៃព្រះសង្ឃទាំងអស់នោះ ដោយសេចក្ដីគោរពកោតក្រែងសព្វ

កាលគ្រប់ទិសទី ។

គុណដ៏ប្រសើរសព្វគ្រប់នៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គក្តី គុណដ៏ប្រសើរសព្វគ្រប់នៃព្រះធម៌ទាំងអស់ក្តី គុណដ៏ប្រសើរសព្វគ្រប់នៃព្រះបច្ចេកពុទ្ធគ្រប់ព្រះអង្គក្តី គុណដ៏ប្រសើរសព្វគ្រប់នៃព្រះអរហន្តគ្រប់ព្រះអង្គក្តី គុណដ៏ប្រសើរសព្វគ្រប់នៃព្រះសង្ឃសាវ័កគ្រប់ព្រះអង្គក្តី ដែលមានក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ឬដែលមានក្នុងសន្តានចិត្តនៃមនុស្សទេវតា មារព្រហ្មទាំងអស់ ក្នុងចក្រវាលនេះក្តី ក្នុងចក្រវាលដ៏ទៃទៀតក្តី យើងខ្ញុំសូមនមស្ការនូវគុណដ៏ប្រសើរសព្វគ្រប់ទាំងអស់នោះដោយសេចក្តីគោរពកោតក្រែងសព្វកាលគ្រប់ទិសទី ។

ព្រះសម្មាសម្ពុទ្ធទាំងឡាយទ្រង់មានញាណជាគ្រឿងដឹងសព្វគ្រប់មិនមានសេសសល់ គ្រឿងរារាំងក្នុងញាណនោះមិនមានទេ គឺព្រះសព្វញ្ញុពុទ្ធទាំងឡាយទ្រង់ជ្រាប

សព្វគ្រប់នូវហេតុជាអតីត អនាគត បច្ចុប្បន្ន ព្រោះហេតុនោះសូមព្រះសព្វញ្ញុពុទ្ធគ្រប់ព្រះអង្គមេត្តាទទួលនូវកិរិយានមស្ការថ្វាយបង្គំ ការសសើរ ការបូជានូវសក្ការៈទាំងឡាយ ទាំងអាមិសបូជា ទាំងបដិបត្តិបូជា អំពីយើងខ្ញុំទាំងឡាយ ដោយញាណដ៏ប្រសើររបស់ព្រះអង្គ ដោយសេចក្តីអនុគ្រោះផងចុះ។

**គាថាពោលសរសើរព្រះគុណព្រះសម្មាសម្ពុទ្ធជាម្ចាស់**

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
សព្វញ្ញូសិ មហាវីរ លោកជេដ្ឋ នរាសភ ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គទ្រង់មានព្យាយាមធំជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញុពុទ្ធ។

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
ពហុជ្ជនំ តារយសិ ទេសេន្តោ អមតំ បទំ ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ ព្រះអង្គកាលសម្តែងនូវអមតបទ គឺព្រះនិព្វានញ៉ាំងជនដ៏ច្រើនឱ្យឆ្លងវដ្តៈទុក្ខបាន ។

**រូបេ សីលេ សមាធិម្ហិ បញ្ញាយ ច អសាទិសោ**

**វិមុត្តិយា អសមសមោ ធម្មចក្កប្បវត្តនេ ៗ**

ព្រះអង្គមិនមានបុគ្គលស្មើក្នុងព្រះរូបផង សីលផង សមាធិផង បញ្ញាផង ព្រះអង្គស្មើរដោយព្រះពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើរ ចំពោះវិមុត្តិធម៌ និង ការញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅ ។

**លាភាលាភេ ន សជ្ជន្តិ សម្មានេ វិមាននេ**

**បឋវីសទិសា ពុទ្ធា តស្មា តេ ន វិរោធិយា ៗ**

ព្រះពុទ្ធទាំងឡាយ មានចិត្តស្មើរដោយផែនដី មិនជាប់ជំពាក់ក្នុងលាភ និង អលាភ ក្នុងការរាប់អាន ក្នុងការមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឱ្យឆ្គាំឆ្គងនឹងព្រះ

ពុទ្ធទាំងនោះឡើយ ។

## ម្ភៃឆ្នាំពីរតែរបែរ

មាត់សូត្ររំលឹក នឹកព្រះភគវា
តែបែរនិន្ទា យកគ្នាជាខ្មាំង
កាយក្រាបសំពះ អង្គព្រះអរហំ
តែបែរបិទបាំង កាយសំសត្ថ: ។
ស្លៀកសពាក់ស លម្អដោយសីល
តែបែរចិត្តខិល មន្ទិលពព្លាក់
រៀនសូត្រខំប្រឹង ចេះដឹងជ្រៅរាក់
តែបែរជាទាក់ លាភៈលោភោ ។
ខំប្រឹងឱ្យទាន មិនហ៊ានកំណាញ់
តែបែរជាចាញ់ ស្រទ្បាញ់បញ្ចោរ
ទេស្នាធម្មទាន និព្វានហៃហូរ
តែបែរលោកគ្រូ ជោរនឹងកេរ្តិ៍ឈ្មោះ ។
ទ្រទ្រង់វិន័យ សិរីជ័យជោគ

តែបែរគោះខោក ដាក់លោករងគ្រោះ
សូត្រអភិធម្ម ចេះចំឥតខ្វោះ
តែបែរមិនស្មោះ ព្រោះខ្លាចចាញ់ប្រៀប ។
មានមិត្តកល្យាណ គឺបានមង្គល
តែបែរឥតផល រវល់ប្រៀបធៀប
យកធម៌ជាធំ រូងភ្នំស្ងាត់ច្រៀប
តែបែរជាប់កៀប របៀបលើកខ្លួន ។
ពូកែអស្ចារ្យ ការងារគ្រប់យ៉ាង
តែបែរក្អេងក្អាង អាងយ៉ាងមាំមួន
បានទ្រព្យសេដ្ឋី ជោគជ័យស៊ប់សួន
តែបែរគុំកួន គាប់ចួនកំណាញ់ ។
មានបុណ្យមានស័ក្តិ ឥស្សរៈយ៉ាងធំ
តែបែរធ្វើខ្ញុំ បរមអង្គអញ
ឈ្នះមនុស្សលាននាក់ ទោះយក្ខក៏ចាញ់
តែបែរអង្គអញ ចាលចាញ់ខ្លួនឯង ។

កាន់សីលរៀវសាច់ សម្រេចថាសុទ្ធ
តែបែរពោលដុត សម្លុតកំហែង
រៀនធម៌បដិបត្តិ បរមត្ថសម្ដែង
តែបែរវង្វេង លែងដឹងខុសត្រូវ ។
ផ្ដាប់ផ្ដុនអ្នកក្រៅ កូនចៅចិត្តស្មោះ
តែបែរជាទាស់ ឈ្លោះនឹងម៉ែឪ
អ្នកតូចអ្នកធំ រាប់អានត្រឹមត្រូវ
តែបែរអាស្រូវ មិនត្រូវនឹងសង្ឃ ។
អគារត្រង់ខ្ពស់ បានរស់ថ្កើងថ្កាន
តែបែរសន្ដាន មិនបានខ្ពស់ត្រង់
ជួយអ្នកដទៃ លកលៃផ្ចិតផ្ចង់
តែបែរឯកអង្គ លង់ក្នុងកំហុស ។
លោកធម៌លាភយស កេរ្តិ៍ឈ្មោះថ្កុំថ្កើង
តែបែរចេះឡើង ស្ដើងខាងចេះចុះ
ធ្លាប់បានជាធំ ជួបជុំស្រីប្រុស

តែបែរបាត់អស់ ស្រណោះកាមា ។
ស្គាល់មនុស្សទេវតា ហ៊ឺហាក្រៃលែង
តែបែរខ្លួនឯង វង្វេងអាត្មា
ស្រឡាញ់ខ្លួនឯង តាក់តែងកាយា
តែបែរចិន្តា ឧបមាដូចប្រេត ។
ប្រើរបស់ថ្លៃៗ វិស័យអ្នកខ្លាំង
តែបែរហ៊ឺនំ ប្រឆាំងបុញ្ញក្ខេត្ត
ចេតិយព្រះពុទ្ធ ខ្ពស់ផុតត្រដែត
តែបែរមនុស្សប្រេត មិនឆ្អែតនឹងបាប ។
ភ្នែកធំស្អាតថ្លា ទស្សនាប្រចក្ស
តែបែរចិត្តខ្វាក់ ប្រឡាក់គ្រឿងឆ្អាប
ធម្មេក្ខស្តូប គ្រប់រូបសូមក្រាប
បញ្ញាលាងបាប ទឹកសាបសច្ចញ្ញាណ ។
ព្រះកោណ្ឌញ្ញៈ ជាអ្នកដឹងមុន
ទ្រទ្រង់នូវគុណ កបកើយនិព្វាន

ឯហិឆ្លោះត្រង់ ព្រះសង្ឃកើតមាន
ត្រៃសរណញ្ញាណ និព្វានសុខហោង
(កំណាព្យ លោកគ្រូ ប៊ុត សាវង្ស)

# ភទ្ទេករត្តសូត្រ

## ភគវា ឯតទវោច

អតីតំ នាន្វាគមេយ្យ នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ អប្បត្តញ្ច អនាគតំ ។
បច្ចុប្បន្នញ្ច យោ ធម្មំ តត្ថ តត្ថ វិបស្សតិ
អសំហីរំ អសង្កុប្បំ តំ វិទ្វា មនុព្រូហយេ
អជ្ជេវ កិច្ចមាតប្បំ កោជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា
ឯ វំវិហារមាតាបឹ អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ សន្តោ អាចិក្ខិតេ មុនីតិ ។

ប្រែថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បុគ្គលមិនគប្បីអាឡោះអាល័យ បញ្ចក្ខន្ធដែលកន្លងទៅហើយ មិនគប្បីប្រាថ្នាបញ្ចក្ខន្ធដែលមិនទាន់មកដល់ទេ ព្រោះបញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះកន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគតបញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀតបុគ្គលណាឃើញច្បាស់នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះៗ បុគ្គលនោះ លុះបានដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម និងមិនបានកម្រើក (ដោយពួកកិលេស) គប្បីចម្រើនឲ្យរឿយៗ នូវផលសមាបត្តិ ដែលមានព្រះនិព្វាននោះ ជាអារម្មណ៍ ឯការព្យាយាមជាគ្រឿង ដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបានព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នកប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌

យ៉ាងនេះ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់យប់និងថ្ងៃនោះឯងថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

## តាយនសុត្តគាថា

តាយនៈទេវបុត្តពោលនូវគាថាទាំងឡាយនេះក្នុងសម្នាក់នៃព្រះមានព្រះភាគ

ឆិន្ទ សោតំ បរក្កម្ម កាមេ បនូទ ព្រាហ្មណ
នប្បហាយ មុនិ កាមេ នេកត្តមុបបជ្ជតិ។
កយិរា ចេ កយិរាថេនំ ទឡ្ហមេនំ បរក្កមេ
សិថិលោ ហិ បរិព្វាជោ ភិយ្យោ អាកិរតេ រជំ។
អកតំ ទុក្កដំ សេយ្យោ បច្ឆា តប្បតិ ទុក្កដំ
កតញ្ច សុកតំ សេយ្យោ យំ កត្វា នានុតប្បតិ។
កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយុបកឌ្ឍតិ។

យំកិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ។

ប្រែថា បពិត្រព្រាហ្មណ៍ ចូរអ្នកព្យាយាមកាត់ខ្សែរតណ្ហា ចូរអ្នកបន្ទោបង់នូវកាមទាំងឡាយ មុនី(បើ) មិនលះបង់នូវកាមទាំងឡាយទេក៏មិនបាននូវឈាន បុគ្គលបើបានជាធ្វើព្យាយាម កុំគប្បីបន្ធូរបន្ថយព្យាយាមនោះឡើយ គប្បីធ្វើព្យាយាមនោះឲ្យមាំមួនឡើង ព្រោះថាបព្វជាដែលបុគ្គលកាន់ធូរៗ រមែងរោយនូវធូលីគឺកិលេសដ៏ក្រៃលែង អំពើអាក្រក់ដែលបុគ្គលមិនធ្វើហើយ ជាអំពើប្រសើរ អំពើអាក្រក់តែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ មួយទៀតបុគ្គលធ្វើនូវអំពើណា តែងមិនក្តៅតាមអំពើនោះដែលបុគ្គលធ្វើហើយ ជាអំពើល្អប្រសើរ ភាពជាសមណៈដែលអ្នកបួសកាន់មិនល្អ តែងប្រទាញចូលទៅក្នុងនរក ដូចជាស្បូវដែលបុគ្គលកាន់មិនល្អ តែងមុត

ដែដូចច្នោះឯង  ការងារណាមួយដ៏ធូរៗក្ដី  វត្តណាមួយដ៏សៅហ្មងក្ដី ព្រហ្មចរិយធម៌ណាមួយ  ដែលបុគ្គលប្រព្រឹត្ដោយសេចក្ដីរង្កៀសក្ដី  កិច្ចនោះ  ជាកិច្ចមិនមានផលធំឡើយ។

**ខេមាខេមសរណទីបិកគាថា**(ទីពឹងដ៏ក្សេមនិងមិនក្សេម)

ពហុំ វេ សរណំ យន្តិ  បព្វតានិ វនានិ ច

អារាមរុក្ខចេត្យានិ      មនុស្សា ភយតជ្ជិតា។

មនុស្សទាំងឡាយមានចំនួនច្រើន កាលដែលភ័យគ្របសង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយអារាមនិងដើមឈើដែលជាចេតិយទាំងឡាយខ្លះ  ជាទីពឹង។

នេតំ ខោ សរណំ ខេមំ  នេតំ សរណមុត្តមំ

នេតំ សរណមាគម្ម      សព្វទុក្ខា បមុច្ចតិ។

ទីពឹងនុះឯងមិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងនុះមិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលមិនដែលរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុះទេ។

យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ។

បុគ្គលណាមួយបានដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងទីរឭកហើយឃើញនូវអរិយសច្ចទាំង៤ គឺសេចក្តីទុក្ខ១ សមុទយជាដែនកើតឡើងព្រមនៃសេចក្តីទុក្ខ១ និរោធជាទីកន្លងបង់នូវសេចក្តីទុក្ខ១ មគ្គមានអង្គ៨ ដ៏ប្រសើរដែលញ៉ាំងសត្វឱ្យដល់នូវព្រះនិព្វាន ជាឋានរំងាប់បង់នូវសេចក្តីទុក្ខ១ ដោយប្រាជ្ញាដ៏ត្រូវ។

ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ។

ទីពឹងនុះឯងជាទីពឹងដ៏ក្សេម ទីពឹងនុះជាទីពឹងដ៏ឧត្តម បុគ្គលរមែងរួចស្រឡះចាកទុក្ខទាំងពួងព្រោះអាស្រ័យនូវទីពឹងនុះឯង។ បិ.៥២/៦១

# អភិណ្ហប្បច្ចវេក្ខណៈ

គឺធម៌ដែលគប្បីពិចារណារឿយៗ ដើម្បីការរឹងមាំនៃជីវិត មាន ៥ ប្រការគឺ ៖

១. ជរាធម្មោម្ហិ ជរំ អនតីតោ អាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ។

២. ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ។

៣. មរណាធម្មោម្ហិ មរណំ អនតីតោ អាត្មាអញ មានមរណៈជាធម្មតា មិនកន្លងមរណៈទៅបានឡើយ។

៤. សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ

អាត្មាអញតែងមានការព្រាត់ប្រាសនិរាសចាកសត្វ និង សង្ខារដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង

៥. កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិ- សរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ អាត្មាអញមានកម្មជារបស់ខ្លួន មាន កម្មជាមរតក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើនូវកម្មណា ទោះល្អ ក្តី អាក្រក់ក្តី អាត្មាអញនឹងជាអ្នកទទួលនូវផលនៃកម្ម នោះកាលពិចារណារឿយៗ យ៉ាងនេះ ក៏រមែងជួយការ ពារនូវសេចក្តីស្រវឹង ក្នុងយុវវ័យ ក្នុងទ្រព្យសម្បត្តិ និង ក្នុងជីវិតជាដើម ហើយបានកម្ចាត់បង់នូវសេចក្តីវង្វេង សេចក្តីប្រកាន់ និងកម្ចាត់បង់នូវអំពើទុច្ចរិត ប្រឹងប្រែង ប្រព្រឹត្តតែអំពើជាប្រយោជន៍ សព្វៗ កាល ។

## បព្វជិតអភិណ្ហប្បច្ចវេក្ខណធម្ម ១០

អភិណ្ហប្បច្ចវេក្ខណៈ បានដល់ ធម៌ដែលបព្វជិតគប្បីពិចារណារឿយៗ អភិណ្ហប្បច្ចវេក្ខណៈនោះ មាន ១០ យ៉ាង គឺ៖

១. វេវណ្ណិយម្ហិ អជ្ឈុបគតោតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិត គប្បីពិចារណារឿយៗ ថា អាត្មាអញកាន់យកនូវភេទដ៏ប្លែក អំពីភេទរបស់គ្រហស្ថ។

២. បរប្បដិពទ្ធា មេ ជីវិកាតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិតគប្បីពិចារណារឿយៗ ថា ការប្រព្រឹត្តចិញ្ចឹមជីវិតរបស់អាត្មាអញប្រព្រឹត្តជាប់ ដោយបុគ្គលដទៃ។

៣. អញ្ញោ មេ អាកប្បោ ករណីយោតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិតគប្បីពិចារណារឿយៗ ថា អាកប្បកិរិយាផ្សេងអំពីគ្រហស្ថ អាត្មាអញគួរធ្វើ។

៤. កច្ចិ នុ ខោ មេ អត្តា សីលតោ ន ឧបវទតីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិតគប្បីពិចារណារឿយៗ ថា

អាត្មាអញមិនតិះដៀលខ្លួនឯង ដោយសីលបានទេឬ ?
៥. កច្ចិ នុ ខោ មំ អនុវិច្ច វិញ្ញូ សព្រហ្មចារី សីលតោ ន ឧបវទន្តី តិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិតគប្បីពិចារណារឿយៗ ថា ពួកសព្រហ្មចារី ជាវិញ្ញូជន ពិចារណាហើយមិនតិះដៀលអាត្មាអញ ដោយសីលបានទេឬ ?
៦. សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិតគប្បីពិចារណារឿយៗ ថា ការព្រាត់ប្រាសនិរាសចាកសត្វ និងសង្ខារទាំងអស់ ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្ត នៃអាត្មាអញតែងមានជាធម្មតា។
៧. កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិតគប្បីពិចារណារឿយៗ ថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅ

ពង្ស មានកម្មជាគ្រឿងរលឹកឃើញ អាត្មាអញនឹងធ្វើនូវកម្មណា ល្អ ឬអាក្រក់ អាត្មាអញគង់នឹងបានជាអ្នកទទួលយកនូវផល នៃកម្មនោះពុំខានឡើយ។

៨. កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិតគប្បីពិចារណារឿយៗថាយប់និងថ្ងៃទាំងឡាយចេះតែកន្លងទៅៗ តើអាត្មាអញ បានធ្វើអ្វីខ្លះ

៩. កច្ចិ នុ ខោហំ សុញ្ញាគារេ អភិរមាមីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិតគប្បីពិចារណារឿយៗ ថា អាត្មាអញមានសេចក្តីអភិរម្យ ត្រេកអរក្នុងផ្ទះដ៏ស្ងាត់ខ្លះដែរឬទេ ?

១០. អត្ថិ នុ ខោ មេ ឧត្តរិមនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ សោហំ បច្ឆិមេ កាលេ សព្រហ្មចារីហិ បុដ្ឋោ ន មង្កុ ភវិស្សាមីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បព្វជិតគប្បីពិចារណារឿយៗ ថា ឧត្តរិមនុស្សធម៌ គឺ ធម៌ជារបស់មនុស្សដ៏ប្រសើរក្រៃលែង មានដល់អាត្មាអញដែរឬ ធម៌ដ៏វិសេស ដែលគួរនឹងឃើញ ដោយប្រាជ្ញាដ៏ប្រសើរ អាត្មា

អញបានត្រាស់ដឹងហើយឬ អាត្មាអញនោះសព្រហ្មចារី ទាំងឡាយសួរក្នុងកាលជាទីបំផុត (មរណសម័យ) នឹងមិនអឹមអៀមទេឬ ?(អង្គុត្តរនិកាយ ទសកនិបាត លេខ ៥០ ទំព័រ ១៨៨ ដល់ ១៩០)

## ធម្មនិយាម ៣០

សូមក្រាបបង្គំ ប្រណម្យវន្ទា
ឆ្ពោះព្រះភគវា ពុទ្ធាបានត្រាស់
ធម្មនិយាម ទំនៀមល្អល្អះ
សាមសិបមុខច្បាស់ ខ្ញុំសូមពណ៌នា។
មួយរញ្ជួយភព ជាតិគ្រប់ចុងក្រោយ
បារមីនាំឱ្យ ដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃ ស្មារតីល្អជា
ដឹងខ្លួនគ្រប់គ្រា ក្នុងគភ៌មាតា។
ពីរគឺព្រះភក្ត្រ វរលក្ខណ៍ក្នុងគភ៌

ស្មឹងស្មាធិ៍ក្នុងធម៌ បវរកាយា
ព្រះភក្ត្របែរផ្ទុយ ពីខ្នងមាតា
ឆ្ពោះផ្ទៃភ្លឺថ្លា មាតារំពៃ។
បីឥរិយាបថ នៃព្រះមាតា
ពេលគ្រប់មាសា សាស្តាចាកផ្ទៃ
មាតាទ្រង់ឈរ ខុសស្រីដទៃ
ប្រសូត្របុត្រថ្លៃ ហប្ញទ័យជ្រះថ្លា។
បួនសួនឧទ្យាន ទីឋានប្រសូត្រ
ក្នុងព្រៃរហូត ឈើស្រូតចេញផ្កា
ទេវតានិងមនុស្ស ថ្វាយសាធុការ
ចក្រវាឡបព្វតា ខ្ទរខ្ទារអ៊ូអរ។
ប្រាំព្រះប្រសូត្រ ចុះស្រូតយាងឈាន
ប្រាំពីរជំហាន ឆ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋាន ក្លាហានបវរ
ទើបបានបន្ត បន្លឺសីហនាទ។

ប្រាំមួយប្រមើល ទតមើលនិម្មិត
ទេវទូតបួនពិត ចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណា ថ្ងៃនោះទ្រង់ឃ្លាត
ចិត្តឥតរវាត យាត្រាសាងផ្នួស។
ប្រាំពីរធីរោ ផ្តាច់ប្តូរព្យាយាម
ឥតមានទាក់ទាម ក្នុងនាមអ្នកបួស
កំណត់វេលា មិនអាចតិចហួស
ប្រាំពីរថ្ងៃនោះ នឹងបានត្រាស់ដឹង។
ប្រាំបីមហេសី គង់សោយបាយាស
ក្នុងថ្ងៃបានត្រាស់ ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាស ថ្វាយព្រះថ្ងៃហ្នឹង
ហៅបាយត្រាស់ដឹង បានបានបុណ្យមហិមា។
ប្រាំបួនជួនភ័ព្វ ទ្រង់ទ្រាប់ស្បូវភ្លាំង
ក្លាយជាបល្ល័ង្ក គង់តាំងភាវនា
នៅគល់ពោធិព្រឹក្ស នាទិសបូព៌ា

បល្ល័ង្កភគវា ផុសគ្រាសាយណ្ហៅ។
ដប់គាប់ហឫទ័យ អានាបាណៈ
បរិកម្មប្រចក្ស សតិដឹងទាន់
ខ្យល់ចេញខ្យល់ចូល ចិត្តមូលមិនភាន់
ដំណើរជវ័ន ជាន់ឆ្លងកាមា។
ដប់មួយជំនួយ ពីព្រះបារមី
ផ្ចាញ់មារអប្រីយ៍ ព្រមទាំងសេនា
ពុទ្ធប្បវត្តិ ត្រង់នេះអស្ចារ្យ
បរិស័ទជ្រះថ្លា បាចផ្កាអភិសេក។
ដប់ពីរមុនីអង្គ ទ្រង់សម្រេចញាណ
ត្រៃវិជ្ជាមាន ទ្រង់ញាណអនេក
វិសាខបុណ្ណមី កើតញាណប្លែកៗ
ពោធិញ្ញាណខ្ពស់ឯក កក្រើកធរណី។
ដប់បីក្សត្រថ្លៃ គង់ក្នុងមហាឋាន
វិមុត្តក្សេមក្សាន្ត អស់ឋានប្រាំពីរ

សប្តាហ៍បានមួយ លើកស្អួយបានទី
ចេតិយមុនី ប្រាំពីរកន្លែង។
ដប់បួនជួនព្រហ្ម ជុំអារាធនា
សូមព្រះភគវា យាងត្រាស់សម្តែង
ព្រះធម៌ប្រពៃ វិស័យស្ញប់សែង
ទ្រង់ព្រមសម្តែង ដោយព្រហ្មវិហារ។
ដប់ប្រាំចាំច្បាស់ ទ្រង់ត្រាស់ធម្មចក្ក
ឥសិបតនៈ ព្រៃមិគទាយា
បានត្រៃរតនៈ អាឡ្ហបូជា
ថ្ងៃព្រះភគវា ស្ថាបនាព្រះសង្ឃ។
ដប់ប្រាំមួយទ្រង់ គង់ត្រាស់ឱវាទ
បាតិមោក្ខស្អាងស្អាត ឱវាទផូរផង់
បេះដូងព្រះធម៌ ពន្លឺចតុរង្គ
ថ្ងៃនោះត្រូវត្រង់ មាឃបុណ្ណមី។
ដប់ប្រាំពីរទ្រង់គង់ វត្តជេតពន

ប្រោសដល់មហាជន និរន្តរ៍ប្រក្រតី
ទ្រង់យកអរុណ ជេតពនសួស្តី
ជេតពនជិនស្រី អាស្រ័យជានិច្ច។
ដប់ប្រាំបីទ្រង់ សម្តែងបាដិហារ្យ
យមកៈអស្ចារ្យ និគ្រន្ថរត់គេច
នៅក្រុងសាវត្ថី ប្រុសស្រីមិនតិច
នេះគឺពុទ្ធកិច្ច សង្គ្រោះលោកា។
ដប់ប្រាំបួនទ្រង់ គង់ឋានត្រៃត្រឹង្ស
ត្រិះរិះរំពឹង ថ្លឹងគុណមាតា
សម្តែងអភិធម្ម ស័ក្តិសមអស្ចារ្យ
ថ្វាយព្រះមាតា សុខាអមតៈ។
ម្ភៃគឺព្រះអង្គ ទ្រង់ចាកទេវលោក
ស្តេចយាងចុះមក ដែនសង្កស្សៈ
មហាជនច្រើនពិត យកចិត្តទុកដាក់
បូជាគារវៈ អចលចេតិយ។

ម្តងមួយគឺទ្រង់ គង់ក្នុងសមាបត្តិ
ព្រះញាណស្ងប់ស្ងាត់ លះកាត់លោកីយ៍
អរហត្តផល តម្កល់ប្រក្រតី
ឆាប់ក្តីយូរក្តី វិស័យពុទ្ធញាណ។
ម្តងពីរប្រមើល មើលគ្រប់វេនយ្យ
ឧបនិស្ស័យ សព្វសត្វដែលមាន
ដោយព្រះករុណា សមាបត្តិញ្ញាណ
ត្រួតសត្វកោដិលាន មានពីរវារៈ។
ម្តងបីទ្រង់លៃ វិន័យអាជ្ញា
បញ្ញត្តសិក្ខា តាមការជ្រាបជាក់
មានរឿងកើតមុន ខូតគុណសាវ័ក
មានហេតុជាក់លាក់ ទើបដាក់វិន័យ។
ម្តងបួនអង្រួន ហឫទ័យករុណា
ជាតកទេសនា សាស្តាលកលៃ
ដើមរឿងជាហេតុ បង្កើតអត្ថន័យ

ជាតកប្រពៃ លៃតាមហេតុការណ៍។
ម្តេចប្រាំទ្រង់ប្រោស ដល់ពួកព្រះញាតិ
អង្គព្រះលោកនាថ សម្តែងបាដិហារ្យ
កម្ចាត់មានះ ព្រះញាតិវង្សា
ទើបត្រាស់ទេសនា គម្ពីរពុទ្ធពង្ស។
ម្តេចប្រាំមួយទ្រង់ គង់ធ្ងន់ក្នុងធម៌
បរិស័ទណាល្អ មានធម៌ទ្រទ្រង់
ស្តេចយាងទទួល ស្រុះស្រួលដោយអង្គ
គារវៈផ្សរផង់ ឆ្ពោះត្រង់ព្រះធម៌ ។
ម្តេចប្រាំពីរទ្រង់ គង់ចាំវស្សា
បើមាននរណា និមន្តដោយល្អ
ពេលចេញវស្សា មុនយាងចេញចរ
ទ្រង់ចម្រើនពរ ត្រាស់លាអ្នកនោះ ។
ម្តេចប្រាំបីទ្រង់ គង់យ៉ាងហ្មត់ចត់
មុនភត្តក្រោយភត្ត គ្មានភ្លាត់ភ្លេចសោះ

បំពេញពុទ្ធកិច្ច គ្រប់យាមទាំងអស់
ពុទ្ធកិច្ចសង្គ្រោះ មនុស្សនិងទេវតា។
ម្ភៃប្រាំបួនទ្រង់ គង់សោយមំសៈ
ក្នុងថ្ងៃទ្រង់ដាក់ អនុដ្ឋានកាយា
បិណ្ឌបាតចុងក្រោយ ជាទានថ្ងៃថ្លា
សោយរសមំសា ហឫទ័យបរិសុទ្ធ។
សាមសិបអវសាន ទ្រង់បានចូលឈាន
មុននឹងនិព្វាន ឈានច្រើនបំផុត
ម្ភៃបួនសែនកោដិ សមាបត្តិបរិសុទ្ធ
រួចហើយទ្រង់ផុត រលត់សង្ខារ។

អហំ វីខ្ញុំបង្គំវន្ទា

ឆ្ពោះព្រះភគវា ព្រះធម៌ថ្លៃថ្លា
ព្រមទាំងព្រះសង្ឃ ផូរផង់សីលា
ចិន្តាលំអុត ព្រះពុទ្ធនិយាម។
សូមឱ្យសព្វសត្វ បដិបត្តិតាមធម៌

សាសនាបវរ ល្អដូចព្រះនាម
អរហំសម្មា គ្មានការទាក់ទាម
កិលេសរវាម រវាតសូន្យបង់។
សូមឱ្យសាសនា សម្មាសម្ពុទ្ធ
បរិស័ទមោះមុត រួមចិត្តទ្រទ្រង់
ឋិតថេរចិរកាល អភិបាលដោយសង្ឃ
ព្រមព្រៀងស្មោះត្រង់ ផ្ចិតផ្ចង់សិក្ខា។
សូមមនុស្សទេវតា មានការគោរព
ទាំងថ្ងៃទាំងយប់ ក្នុងព្រះសាសនា
សូមបានសម្រេច ដូចក្តីប្រាថ្នា
អស់នូវតណ្ហា ទុក្ខាចប់ហោង។

**សទ្ធម្មដ្ឋិតិកាមេន កតោ គន្ថោ ច យំ មយា**
**បុញ្ញមធិគតំ តេន សុខំ បប្បោន្តុ បាណិនោ។**

ខ្ញុំអ្នករចនាដែលប្រាថ្នាការតាំងនៅនៃព្រះសទ្ធម្ម បានប្រសព្វនូវបុណ្យណា សូមសត្វទាំងឡាយ ចូលបាននូវសេចក្តីសុខ ដោយបុណ្យនោះចុះ។

**ឥមិនា រចនេន តុ សព្វេ សត្តា សុខី ហោន្តុ**
**កម្ពុជរដ្ឋវាសិនំ សន្តិតាវោ សទា ហោតុ។**

ដោយការរចនាសៀវភៅនេះ សូមសព្វសត្វទាំងអស់ប្រកបតែសេចក្តីសុខ សូមសន្តិភាពកើតមានដល់ប្រជាជនអ្នករស់នៅក្នុងដែនកម្ពុជា គ្រប់ៗកាល។

សូមឱ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឱ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឱ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា នត្ថិ សន្តិ បរំសុខំ ពុំមានសេចក្តីសុខដទៃក្រៅអំពី សេចក្តីស្ងប់ឡើយ។

សូមពុទ្ធបរិស័ទទាំងអស់ បានភប់ប្រសព្វជួបប្រទះតែនឹងពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈគ្រប់ទិនទិវារាត្រីកុំបីឃ្លៀងឃ្លាតឡើយ! សូមសព្វសត្វនិករទាំងអស់បានជួបតែនឹងសេចក្តីសុខសន្តិភាពគ្រប់ប្រការ រួចផុតចាកទុក្ខ សោក រោគ ភ័យ តរៀងទៅ! សូមសច្ចធម៌នៃព្រះបរមគ្រូសម្មាសម្ពុទ្ធបានជ្រួតជ្រាបក្នុងដួងចិត្តនៃប្រជាបរិស័ទគ្រប់រូបជានិរន្តរ៍តរៀងទៅហោង! *សូមអនុមោទនា!!!*



កាលបើក្រុងមារក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏បានត្រាស់ភាសិតនេះទៅនឹងក្រុងមារមានចិត្តបាបថា ‘ ម្នាលមារមានចិត្តបាប អ្នកចូរមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគតមិនយូរប៉ុន្មានទេកន្លងពាខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយៗ